# កិច្ចសំភាសន៍របស់អ៊ុំស្រីឈ្មោះ កែ អូយ

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវសំភាសន៍ឈ្មោះ កែ អូយ

កៈ ចាសជំបូងខ្ញុំសូមជំរាបសួរអ៊ុំ!

ខៈ ចាស លើកដៃថ្វាយព្រះក្មួយ! អ....(សើច)

កៈ ចាសអ៊ុំច្រើនអ៊ុំដែលថ្ងៃនេះខ្ញុំមានឪកាសដើម្បីនឹងសំភាសន៍អ៊ុំ ចាសហើយអឺ...អ៊ុំស្រីថ្ងៃនឹងសុខសប្បាយដែរឬទេអ៊ុំ?

ខៈ សុខសប្បាយទេ ប៉ុន្តែជីចូលភ្នែកបន្តិចហើយ(សើច)!

កៈ (សើច)ម៉េចចឹងអ៊ុំកើតអីដែរ?

ខៈ ចេះតែញ័រក្នុងខ្លួនទៅណាស់

កៈ អូ....(សើច)!

ខៈ មែនញ័រមែនណាស់ ពេលណានេះទៅចេះតែញ័រចឹងទៅណាស់!

កៈ ចាសហើយអឺ....

ខៈ ដូចថាយើងវាអាយុច្រើនហើយណាស់!

កៈ ចាស!

កៈ ទៅត្រង់ណាទៅវាអស់វាអន់អី ល្មមៗនឹងញ័រទៅ!

កៈ ចាសអ៊ុំស្រី ហើយថ្ងៃនេះខ្ញុំមកធ្វើការសំភាសន៍អ៊ុំទាក់ទងជាមួយនឹងពង្សប្រវត្តិរបស់អ៊ុំ ប្រវត្តិអឺ...ជីវប្រវត្តិហើយនឹងបទពិសោធន៍ដែលអ៊ុំធ្លាប់មានតាំងពីមុនរហូតមកដល់ឥលូងនឹង ថាតើអ៊ុំស្រីមានបទពិសោធន៍ជីវិតអីគេខ្លះដែលអ៊ុំធ្លាប់បានឆ្លងកាត់មកដើម្បីនឹងចងក្រងជាឯក សារដើម្បីនឹងទុកអោយកូនចៅជំនាន់ក្រោយជាពិសេសកូនចៅរបស់អ៊ុំស្រីផ្ទាល់ដែលគេអាចនឹ ងបើកស្តាប់ហើយនឹងគេអាចចូលទៅក្នុងវេបសាយរបស់ខាងសាលានឹងទៅ គ្រាន់គាត់វាយ

ខាងក្រោយចឹងណាស់អ៊ុំគាត់នឹងអាចទៅហើយនឹងឃើញនូវសំលេងរបស់អ៊ុំស្រីហើយ! ហើយអឺ...អ៊ុំថ្ងៃនេះ....

ខ៖ អឹម! ក្មួយហើយនិយាយចឹងៗអីខ្ញុំស្ដាប់មិនបានទេ!

ក៖ (សើច) ចាសអ៊ុំមិនអីទេ ចាំខ្ញុំកត់អោយក្រោយទៀត!

ខ៖ មែនតើអត់ចេះទេ ស្ដាប់អត់បានទេ អាវែងនែ(ភាសាតំបន់) ដូចនិយាយភាសាអីចឹងណាស់!

ក៖ ចាសៗ!

ខ៖ យើងមិនអាចស្ដាប់បានទេ បើក្មេងជំនាន់មុនៗនឹងអត់ចេះអក្សរផងនឹង(សើច)!

ក៖ (សើច)!

ខ៖ អត់ចេះអក្សរទេ ចេះតិចតួច!

ក៖ ចាសចឹងចាំខ្ញុំធ្វើការបញ្ជាក់ខាងក្រោយហើយនឹងកត់អីចឹងទៅណាស់!

ខ៖ នឹងហើយ!

ខ៖ អោយទៅអ៊ុំបន្ថែមទៀតដើម្បីអោយអ៊ុំស្រណុកទុកជាឯកសារ ហើយអឺ...ថ្ងៃនេះខ្ញុំចង់សុំអនុញ្ញាតដើម្បីអោយអឺ...សំភាសន៍អ៊ុំហើយនឹងថតសំលេងរបស់អ៊ុំយកទៅដាក់នៅខាងវេបសាយរបស់សាលានឹងហើយតើអ៊ុំអនុញ្ញាតអោយខ្ញុំបានសំភាសន៍នៅថ្ងៃនេះដែរឬទេអ៊ុំ?

ខ៖ នឹងហើយក្មួយ និយាយមើលសំភាសន៍មើលថាទៅមើលហ៍(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសអ៊ុំអរគុណច្រើនចឹងមុនដំបូងនៃការសំភាសន៍(សំលេងឆ្កែព្រូស) ថ្ងៃនេះគឺថ្ងៃទី០៨ ខែ៧ ឆ្នាំ២០១៨ ហើយថ្ងៃនេះផងដែរខ្ញុំមានឪកាសដើម្បីនឹងសំភាសន៍អ៊ុំតែម្ដងហើយការសំភាសន៍មួយនេះជាមុនដំបូងនៃការសំភាសន៍នឹងគឺខ្ញុំសូមសួរឈ្មោះរបស់អ៊ុំស្រីជាមុនសិនតើអ៊ុំមានឈ្មោះអីដែរ?

ខ៖ ខ្ញុំឈ្មោះ អ៊ូយ ខ្ញុំណាស់!

ក៖ ចាស!

ខ៖ ខ្ញុំឈ្មោះអ៊ូយ!

កៈ ចាសអ៊ុំហើយទៅនាមត្រកូលរបស់អ៊ុំ ឈ្មោះទាំងនាមត្រកូលរបស់អ៊ុំចឹងណាស់អ៊ុំ?

ខៈ នឹងហើយខ្ញុំឈ្មោះ កែ អ៊ូយ ខ្ញុំ!

កៈ ចាសហើយទៅឈ្មោះរបស់អ៊ុំនឹងត្រូវនឹងអត្តសញ្ញាតប័ណ្ណដែរឬទេអ៊ុំ?

ខៈ ចាសត្រូវនឹងអត្តសញ្ញាណប័ណ្ណ!

កៈ ចាស!

ខៈ យកអត្តសញ្ញាណប័ណ្ណនឹងឯង ឈ្មោះរបស់ខ្ញុំនឹងដាក់នៅក្នុងអត្តសញ្ញាណប័ណ្ណចឹង!

កៈ ចាសអ៊ុំ ហើយទៅឈ្មោះរបស់អ៊ុំនឹងមានឈ្មោះហៅក្រៅដែរឬទេ?

ខៈ អត់មានទេ!

កៈ អត់មានទេន៍អ៊ុំ?

ខៈ នឹងហើយ អត់មានទេ(សំលេងរំខានពីខាងក្រៅ)!

កៈ ចាសហើយទៅឈ្មោះរបស់អ៊ុំអ្នកណាជាអ្នកដាក់អោយអ៊ុំដែរ?

ខៈ ម៉ែជាអ្នកដាក់ឈ្មោះនឹងអោយ!

កៈ ឪពុកម្ដាយជាអ្នកដាក់ឈ្មោះនឹងអោយទៅអ៊ុំ?

ខៈ នឹងហើយ!

កៈ កាលពីជំនាន់មុនហ៏ ហើយអឺ...គាត់មានបានប្រាប់អ៊ុំថាឈ្មោះរបស់អ៊ុំនឹងមានអត្ថន័យយ៉ាងម៉េចដែរឬទេ?

ខៈ អើយមិនដឹងថាមានអត្ថន័យថាម៉េចទេគាត់អត់មានប្រាប់ថាម៉េចផង....

គៈ ឈឺពោះ(សំលេងអ្នកខាងក្រៅ)!

ខៈ គាត់ដាក់ឈ្មោះមកចឹងតែម្ដងនឹង!

កៈ អឺម!

ខៈ បងឈ្មោះណៃអៀក ណៃអ៊ូយអីចឹងទៅណាស់!

កៈ ចាសគាត់ដាក់ឈ្មោះអោយជូនគ្នាហ៏អ៊ុំ?

ខ៖ នឹងហើយ!

ក៖ ចាស!

ខ៖ គាត់ដាក់ឈ្មោះនឹងអោយជូនគ្នា!

ខ៖ ចាស!

ក៖ (សើច)!

ក៖ ចាសអ៊ុំ ហើយអ៊ុំស្រីសព្វថ្ងៃមានទីលំនៅៗឯណាដែរ?

ខ៖ នៅកំពង់ធំ!

គ៖ ភូមិស្រយ៉ូវជើង(សំលេងពីខាងក្រៅ)!

ខ៖ ភូមិស្រយ៉ូវជើង!

គ៖ ឃុំស្រយ៉ូវ(សំលេងមនុស្សស្រី)!

ខ៖ នឹងហើយឃុំស្រយ៉ូវ ស្រុកស្ទឹងសែន!

ក៖ ចាស!

គ៖ ខេត្តកំពង់ធំ(សំលេងមនុស្សស្រី)!

ខ៖ (ក្រហែម និងសើច) ខេត្តកំពង់ធំ!

ក៖ (សើច) ចាសអ៊ុំហើយសព្វថ្ងៃអ៊ុំមាននៅនឹងហើយទៅស្រុកកំណើតនៅនឹងដែរឬក៏ម៉េចដែរអ៊ុំ?

ខ៖ មិនមែនទេ ខ្ញុំស្រុកកំណើតនៅខាងភូមិកងមាស ហើយទៅពេលដែលខ្ញុំបានប្តីទៅក៏ទៅនឹងឯភូមិស្រយ៉ូវជើងនឹង!

ក៖ អូ...ចឹងស្រុកកំណើតរបស់អ៊ុំស្រីអាចបញ្ជាក់បានដែរឬទេ ថានៅភូមិឃុំស្រុកណាដែរ?

ខ៖ ចាំមើលណាស់ វាស្គាល់តែភូមិៗ នៃអឺ...កងមាសនឹងឯងទៅ ហើយដល់ពេលដែលយើងមកនៅយូរៗទៅវាភ្លេច អឹមឃុំត្នោតជុំចឹងហី ស្រុកបារាយណ៍...

គ៖ ចាស(សំលេងមនុស្សស្រី)!

ខ៖ ខេត្តកំពង់ធំ ចឹង(សើច)នៅចាំដែរតើ(សើច)!

ក៖ (សើច)!

ខ៖ នឹងហើយ!

ក៖ ចាសអ៊ុំ!

ខ៖ ចេះតែថាៗទៅរកនឹកឃើញដែរណាស់!

ក៖ នឹងហើយចេះរកនឹកឃើញវិញន៍អ៊ុំ?

ខ៖ ចាស!

ក៖ ចុះអ៊ុំហើយឥលូវនឹងស្រុកកំណើតរបស់អ៊ុំនឹងអ៊ុំមានដែលទៅលេងឬក៏ធ្លាប់ដែលបានទៅដែរឬទេអ៊ុំ?

ខ៖ ទៅលេង ម្ដាយនៅនឹងម្ដាយរបស់ខ្ញុំនឹងគាត់បានស្លាប់បាត់ហើយ គាត់ស្លាប់នៅប្រាំងមិញនឹងណាស់ខែប៉ុន្មានទេ...ខែពីរខែបីនឹងគាត់ស្លាប់ណាស់!

ក៖ នៅក្នុងឆ្នាំនឹងន៍អ៊ុំ?

ខ៖ នៅក្នុងឆ្នាំនឹង គាត់អាយុ៩៨ឆ្នាំគាត់ស្លាប់!

ក៖ ចាស!

ខ៖ គាត់ស្លាប់នៅអាយុ៩៨ឆ្នាំណាស់ គាត់អាយុច្រើនណាស់!

ក៖ គាត់....

ខ៖ ខ្ញុំទៅមើលថៃគាត់រហូតទាល់តែគាត់ខូច ខ្ញុំនៅមើលថៃគាត់នឹង!

ក៖ គាត់ស្លាប់នឹងនៅក្នុងព្រះជន្មប៉ុន្មានដែរអ៊ុំ?

ខ៖ ៩៨ឆ្នាំ!

ក៖ អាយុរបស់គាត់៩៨ឆ្នាំ!

ខ៖ អាយុ៩៨ឆ្នាំណាស់!

កៈ អូ...គាត់អាយុវែងណាស់ន៏!

ខៈ ចាស(សំលេងរំខានពីខាងក្រៅ)!

កៈ ចាសចឹងលោកយាយត្រូវម្តាយរបស់អ៊ុំនឹងគាត់មានឈ្មោះអីដែរ?

ខៈ គាត់ឈ្មោះ ទន់ គាត់មានឈ្មោះ ទន់!

កៈ ទាំងនាមត្រកូលរបស់គាត់ណាស់អ៊ុំ?

ខៈ ស្អីទេអី.....

កៈ គាត់ហៅថាលោកយាយទន់ ប៉ុន្តែនាមត្រកូលរបស់គាត់!

ខៈ អូ...ខ្ញុំអត់ស្គាល់តាយាយនឹងសោះ បើៗនែ....ម្តាយខាងម៉ែស្គាល់ តាៗភេន លោកយាយមុច អឹម!

កៈ ចាស!

ខៈ អឹម! អត់ស្គាល់មានត្រកូលរបស់គាត់ទេ!

គៈ អូ...ឈ្មោះនាមត្រកូលរបស់ម៉ាមិញឈ្មោះ ម៉ក់ ភេនទន់ៗ!

កៈ អូ...នឹងហើយ ម៉ក់ ភេន ណាស់គាត់ឈ្មោះ ម៉ក់ ភេនទន់!

កៈ (សើច)!

ខៈ នឹងហើយ!

កៈ ចាសអ៊ុំស្រី ចឹងអី...ហើយទៅគាត់ត្រូវជាម្តាយខាងៗ....

ខៈ គាត់ត្រូវជាម្តាយខាងខ្ញុំ!

កៈ ខាងអ៊ុំ? តែដល់ពេលម្តាយខាងឪពុកវិញ?

ខៈ ម្តាយខាងឪពុកវិញឈ្មោះ...អី...មើល តា....កុងកែៗខាងឪពុករបស់ខ្ញុំណាស់!

កៈ ចាស!

ខៈ កុងកែ ម៉ាហ្វូតនឹងហើយ(សំលេងមនុស្សស្រីសើច)!

កៈ (សើច) ចាសៗអ៊ុំ!

ខ៖ នឹងហើយគាត់ឈ្មោះ កុងកែ ម៉ាហួតនឹង!

ក៖ ចាស ចុះឪពុកម្តាយខាងអឺ....ទាក់ទងជាមួយនឹងស្វាមីរបស់អ៊ុំវិញ?

ខ៖ នឹងហើយ!

ក៖ ពួកគាត់មានឈ្មោះអីដែរ?

ខ៖ ពួកគាត់ឈ្មោះ កុងហាក់ ម៉ាហ៊ន!

ក៖ អូ...ដល់ពេលខាងស្វាមីអ៊ុំចាំច្បាស់ម៉ង(សើច)!

ខ៖ នឹងហើយបើខ្ញុំទៅនៅជាមួយគាត់នឹង!

ក៖ អូ....!

ខ៖ ចាស!

ក៖
ចាសចឹងសព្វថ្ងៃនឹងពួកគាត់មានទីលំនៅៗជាមួយអ៊ុំម៉ងហើយអ៊ុំមើលថៃពួកគាត់ចឹងទៅន៍?

ខ៖ ពួកគាត់ខូចអស់បាត់ហើយ(គាត់ស្លាប់អស់ហើយ)!

ក៖ ចឹង?

ខ៖ នឹងហើយ គាត់ខូច(ស្លាប់) ឆ្នាំទៅមួយឆ្នាំម្នាក់
មុនដំបូងគេនឹងកុងៗបានមួយឆ្នាំម៉ាខូចណាស់!

ក៖ ចាសអ៊ុំ!

ខ៖ អឺម! អឺ....

ក៖ គួរអោយសោកស្តាយមែនទែនណាស់អ៊ុំ!

ខ៖ នឹងហើយរួចបានមួយឆ្នាំទៀតបានមកម៉ែបង្កើតនឹង
អឺ...នឹងបានវេទនាណាស់ក្មួយហើយយើងអត់ណាស់(ដកដង្ហើមធំ)!

ក៖ ចាសអ៊ុំ ហើយសព្វថ្ងៃនេះអ៊ុំស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ខ្ញុំអាយុ ៥០ឆ្នាំជាងហើយ ៥៦ ៥៧ ឆ្នាំហើយខ្ញុំ!

ក៖ ចាសហើយទៅអ៊ុំកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរ?

ខ៖ ហើយវង្វេងអស់ហើយដឹងតែឆ្នាំទេក្មួយ!

ក៖ ម៉េ(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសអ៊ុំ!

ខ៖ វង្វេងហើយ!

ក៖ អ៊ឹម! ហើយចុះឆ្នាំត្រូវជាចន្ទគតិ សុរិយគតិ ឆ្នាំដូចខ្មែរយើងដូចជាសត្វគោសត្វកណ្តុរអីនឹងអ៊ុំមានចាំដែរឬទេថាអ៊ុំកើតនៅក្នុងឆ្នាំណាដែរ?

ខ៖ ខ្ញុំកើតនៅឆ្នាំឆ្លូវ ខ្ញុំ!

ក៖ អ៊ុំកើតនៅក្នុងឆ្នាំឆ្លូវន៍អ៊ុំ?

ខ៖ នឹងហើយ ឆ្នាំគោន៍?

ក៖ ចាសអ៊ុំ!

ខ៖ ឆ្នាំឆ្លូវនឹង!

ក៖ អ៊ឹម! ហើយអឺ....ទាក់ទនជាមួយនឹងក្រុមគ្រួសារអ៊ុំបានរៀបអាពាហ៏ពិពាហ៏នៅក្នុងឆ្នាំណាដែរ?

ខ៖ អ៊ឹម! កាលនឹងឯងដាច់ជំនាន់ប៉ុលពតមួយឆ្នាំនឹងការ(ដាច់ជំនាន់ពលពតមួយឆ្នាំនឹងបានគាត់រៀបការ) មើលណាទេចិតប៉ុន្មានទេ៧៧ទៅក៏មិនដឹងនិងហើយចិតប៉ុន្មានដាច់ប៉ុលពតរួចហើយណាស់ដាច់បានមួយឆ្នាំនឹងណាស់(សំលេងរំខានពីខាងក្រៅ) កុំអីនឹងរៀបនៅក្នុងជំនាន់ប៉ុលពតនឹងបាត់ហើយ ប៉ុន្តែវាដាច់ភ្លាមទៅក៏ឯងនឹងរត់ជិតដាច់ខ្យល់ស្លាប់នឹង(សើច)!

ក៖ (សើច)!

ខ៖ មកពីបារាយណ៍ ចាឡោកណាស់(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសអ៊ុំ អូ...កាលនឹងអ៊ុំពិបាកមែនទែន....

ខ៖ អូ...ពិបាកណាស់ក្មួយហើយរត់កាត់អារែងនៃ(ភាសាតំបន់)បន្លាមកណាស់គេហ៍យួនចូលមកហើយចឹងហើយស្បែកជើងកុំអោយពាក់ក្រមាកុំអោយបង់កជួតក្បាលក្រមាទៅក៏នាំគ្នាមករត់កាត់ព្រៃមកនឹងណាស់(សំលេងកូនក្មេង) ហើយស្រែកទឹកជិតស្លាប់ផឹកទឹកក្របី ផឹកក្របីនោមណាស់ ទឹកនោមក្របីណាស់ដែលយើងវាស្រេកខ្លាំងពេកណាស់!

ក៖ អូ....អ៊ុំ!

ខ៖ មកហើយឆ្កែចចកមួយវ៉ូង អឹម...ឆ្កែចចកមកហើយរួចគ្នានឹងមានតែពីរនាក់រត់ទៅខាងណាទៅពួនៗៗៗរត់ពួនតាមព្រៃចឹងណាស់ អូយ....ទំរាំតែមកដល់លោកអើយ(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាស!

ខ៖ បានជួបគេជួបឯងអរណាស់!

ក៖ អឹម ចុះកាលនឹងស្វាមីរបស់អ៊ុំស្រីគាត់មានឈ្មោះអីដែរ?

ខ៖ កាលនឹងមិនទាន់មានប្ដីទេ(សំលេងរំខានពីខាងក្រៅ) ជំនាន់ប៉ុលពត!

ក៖ អូ...ក្រោយពេលជំនាន់ប៉ុលពតបានអ៊ុំរៀបការ!

ខ៖ រៀបការក្រោយជំនាន់ប៉ុលពតមក!

ក៖ ចាសអ៊ុំ!

ខ៖ រៀបការហើយ គាត់នោះជំលៀសពីភូមិស្រយ៉ូវនឹងទៅក៏ទៅនៅក្នុងភូមិខ្ញុំនឹងឯងទៅក៏បានគ្នានៅនឹងភូមិខ្ញុំឯងកុំអីជំនាន់ប៉ុលពតនឹងគេនៅតែរៀបអោយហើយតើ(សំលេងរំខានពីខាងកក្រៅ) ផ្គូរផ្គងអោយហើយ(សើច) ទទួលដល់ពេលដាច់ទៅមានស្អីទៀត ចប់!

ក៖ ចាស តែអ៊ុំប្រុសត្រូវជាស្វាមីរបស់អ៊ុំស្រីនឹងគាត់មានឈ្មោះអីដែរទៅអ៊ុំ?

ខ៖ គាត់ឈ្មោះ អ៊ឹម!

ក៖ លោកពូអ៊ឹម?

ខ៖ នឹងហើយ!

កៈ ចាសហើយចុះនាមត្រកូលរបស់គាត់វិញអ៊ុំ?

ខៈ នាមត្រកូល ស្រី អ៊ឹម(សំលេងរំខានពីខាងក្រៅ)!

កៈ លោកពូស្រី អ៊ឹម!

ខៈ នឹងហើយក្មួយ!

កៈ ចាសហើយសព្វថ្ងៃគាត់មានអាយុប៉ុន្មានឆ្នាំហើយអ៊ុំ?

ខៈ គាត់អាយុ៦០ឆ្នាំហើយ!

កៈ អ៊ឹម! គាត់អាយុបងអ៊ុំ!

ខៈ ចាស គាត់ឆ្នាំកុរ!

កៈ ចាស!

ខៈ នឹងហើយ គាត់ត្រូវបងខ្ញុំ!

កៈ ចុះនៅពេលដែលអ៊ុំរៀបការនឹងអ៊ុំស្រលាញ់គ្នាឬក៏ឪពុកម្តាយជាអ្នកទុកដាក់អោយ?

ខៈ អូ....ជំនាន់ប៉ុលពតលោកអើយសុទ្ធតែគេផ្គូរផ្គងអោយទេ គេផ្គូរផ្គងតាំងតែពីជំនាន់ប៉ុលពតមកម្លេះណាស់!

កៈ តែមិនទាន់បានរៀបការន៍អ៊ុំ ដល់ពេលដាច់មក....

ខៈ រួចទៅដល់ពេលដាច់ទៅបានរៀបការតាមអាពតនឹងទៅណាស់ ហើយគាត់នោះឆ្នាំកុង ហើយខ្ញុំឯណោះឆ្នាំឆ្លូវ!

កៈ អ៊ឹម!

ខៈ (សើច)!

កៈ (សើច) ចាស!

គៈ ហើយដល់ពេលដែលបានជួបគ្នាទៅកូនមួយកន្ទេល (សំលេងរំខានពីខាងក្រៅ)!

ខៈ (សើច) ហាង!

កៈ (សើច) ចាសហើយទៅអ៊ុំសព្វថ្ងៃនឹងអ៊ុំមានកូនប៉ុន្មាននាក់ហើយ?

ខ៖ អីយ៉ូយកូននោះ ឆ្លៀតចែកព្រៃនឹងអស់ពីរមួយនឹង អាយុ៩ឆ្នាំ អ៎...ប្អូនខែស្កន់ស្លាប់បាត់ទៅកូនដំបូងណាស់ ដល់ពេលដែលមកនៅនឹងស្រយ៉ូវនេះកូនអាយុបានឆ្នាំកូនខ្ញុំនឹងស្លាប់មួយទៀតកូនស្រីណាស់ អានឹងដូចថាយើងអត់មានពេទ្យអីត្រឹមត្រូវណាស់ក្មួយហើយយើងទៅដឹងថាមានគ្រុនឈាមគ្រុនអីឯណាជំនាន់នោះហ៎(សំលេងរំខានពីខាងក្រៅ) ទៅមើលកូនមានទៅជិតដល់ឯណាយើងដូចថាយើងមិនសូវស្គាល់ពេទ្យអញ្ចឹងណាស់!

ក៖ ចាស!

ខ៖ ហើយកូនក៏គ្នាស្លាប់ទៅ!

ក៖ ចឹងអ៊ុំកូនរបស់អ៊ុំសរុបទាំងអស់ប៉ុន្មានអ្នកទៅ?

ខ៖ (ក្រហែម) សព្វថ្ងៃនេះនៅរស់តែ៧នាក់ទេ!

ក៖ ចាសចឹងពួកគាត់ទាំងអស់ប្រាំបីនាក់ប៉ុន្តែគាត់ស្លាប់....

ខ៖ ទាំងអស់ប្រាំបួននាក់!

ក៖ ប្រាំបួននាក់ហ៎?

ខ៖ នឹងឯងស្លាប់ពីរហ៎?

ក៖ ស្លាប់ពីរអ៊ុំន៏?

ខ៖ នឹងហើយ!

ក៖ អឺម!

ខ៖ ខ្ញុំកូនច្រើនណាស់សម្បត្តិមានត្រឹមកូនទេ(សើច)!

ក៖ ហើយអឺ...របស់អ៊ុំដែលស្លាប់នឹងគាត់ស្លាប់ដោយសារតែមូលហេតុអីដែរទៅអ៊ុំ?

ខ៖ គ្នាឈឺ....

ក៖ ចេះតែឈឺ កើតមកឈឺម៉ងហ៎?

ខ៖ មុនដំបូងនឹងវាឈឺដើរទេ គេថាវាគ្រុនឈាមដើរចឹងទៅពេលណាវាឃ្លានចឹងទៅមកពមបាយមួយម៉ាត់ចឹងទៅបៀមមីនឹងឯងណាស់(កូនរបស់គាត់ចូ

លចិត្តបៀមបាយ) បើអាកូនប្រុសមុននឹងវាស្កុន អាប្រាំបួនខែនឹងណាស់ ហ៏ប្រាំបួនថ្ងៃៗទេកូននឹង ទៅក៏ស្កុនស្លាប់បាត់ទៅបើកូនស្រីនេះឯងនេះវាគ្រុនឈាម ពេទ្យដល់រួចទៅពេទ្យគេដឹងថាវាគ្រុនឈាម ពេទ្យនឹងពេទ្យអ៊ុំចឹមើងនេះណាស់មីអូននឹងឯង!

កៈ អឺម!

ខៈ ស្លាប់កូនទៅអើយស្តាយណាស់!

កៈ អឹម ចាស! ខ្ញុំសូមទោសផងអ៊ុំដែលបានលឺអញ្ជឹងណាស់ ហើយអ៊ុំបន្ទាប់មកទៀតអ៊ុំបានកូនក្រោយៗមកទៀតនឹងពួកគាត់មានឈ្មោះអីខ្លះដែរអ៊ុំ?

ខៈ ឈ្មោះបងរបស់គេនោះ ឈ្មោះអៀង ហើយកូនប្រុសបន្ទាប់នឹងឯងនោះវាខ្វេរជើងនោះទៅហៅគ្នាឈ្មោះ អាវេវៗចឹងទៅ រួចមីប្អូននោះបន្ទាប់ពីមីអៀង អឺ...អាវេ នឹងណាស់ទៅដាក់ឈ្មោះអោយជូននឹងមីបងនោះ ឈ្មោះអាង (សើច) មីអាងៗហើយមីបន្ទាប់មកមីដែលបន្ទាប់ស្លាប់នោះណាស់មី....

កៈ អូ....

ខៈ មីអាងហើយបានកាឡាងៗនឹងឯងដែលអាយុបានប្រាំឆ្នាំស្លាប់ណាស់!

កៈ ចាស(សំលេងរំខានពីខាងក្រៅ)!

ខៈ ដល់ពេលបន្ទាប់ពីមីអាងនឹងមកបន្ទាប់មកមីសុខលីម បន្ទាប់ពីសុខលីមមកឈ្មោះស្រីល័ក្ខណ៍ៗនឹងមកបានមី
ស្រីអូននេះឯង(សំលេងរំខានពីខាងក្រៅ)!

កៈ ចាសអ៊ុំ!

ខៈ
ហើយអាៗប្អូននឹងដាក់ឈ្មោះថាអាសុចវេងទេនៅក្នុងជីវជាតិវាណាស់(ឈ្មោះនៅក្នុងសំបុត្រកំណើត)!

កៈ ចាសអ៊ុំ!

ខៈ ដល់ហើយគេឃើញវាសាច់ពេកនោះ គេហៅវាអាជ្រូកៗទៅ!

កៈ (សើច)!

ខ៖ សព្វថ្ងៃនឹងជាប់ឈ្មោះជ្រូកនឹងទៅ!

ក៖ (សើច)!

ខ៖ (សើច)!

ក៖ (សើច) មានសាច់ច្រើនពេក(សើច)!

ខ៖ (សើច) ឥលូវនឹងស្វិត!

ក៖ (សើច)!

ខ៖ អត់សុវមានសាច់ទេ!

ក៖ ចាសចឹងកូនរបស់អ៊ុំមានស្រីប៉ុន្មានប្រុសប៉ុន្មាននាក់ដែរទៅអ៊ុំ?

ខ៖ ស្រីនោះឡើងបួនប្រាំ ហើយប្រុសតែពីរនឹងឯងខ្វេរជើងមួយហើយនឹងអាជ្រូកនឹងឯង!

ក៖ អី....ចាស!

ខ៖ (សើច)!

ខ៖ (សើច) ចឹងបងប្អូនកូនទាំងអស់របស់អ៊ុំដែលរាល់ថ្ងៃនឹងពួកគាត់បានរៀបអាពាហ៍ពិពាហ៍អស់ហើយឬនៅអ៊ុំ?

ខ៖ នៅៗបីនាក់ (សំលេងរំខានពីខាងក្រៅ) នៅមីស្រីល័ក្ខណ៍មួយ នៅមីស្រីអូននេះមួយ(សើច)!

ក៖ (សើច)!

ខ៖ ហើយនឹងអាពៅនឹងអាពៅដែលហៅថាអាជ្រូកៗនឹងណាស់!

ក៖ អឺមចាស!

ខ៖ (សើច)!

ក៖ ហើយពួកគាត់កូនរបស់អ៊ុំទាំងអស់នឹងពួកគាត់បានរៀនចប់អស់ហើយន៍អ៊ុំ?

ខ៖ អូ...រៀនចប់ខ្លះមិនចប់ខ្លះទេក្មួយ ទាំងអស់នឹងកាលនឹងអង្កាល់ពីបងៗនឹងយើងវាក្រពេកណាស់យើងវាអត់ពេកខ្លះទៅក៏រៀនបានត្រឹមថ្នាក់ទីប្រាំពីរ ទីប្រាំ អីនឹង រួចបើមីសុខលីមថ្នាក់ទីប្រាំដែរអត់មានចេះអីសោះសុខលីម(សើច)!

ក៖ ចាសហើយអី...អ៊ុំកូនរបស់អ៊ុំមុនៗពួកគាត់រៀបអាពាហ៍ពិពាហ៍ហើយពួកគាត់នៅតាមខេត្តនឹងនៅឯណាខ្លះទៅអ៊ុំ?

ខ៖ មួយនោះមីបងគេនោះបានប្តីនៅឯខេត្តបាត់ដំបងឯណោះហើយអាបន្ទប់មកនឹងឯងបានប្រពន្ធនៅឯខេត្តកំពតទៅ
ហើយទៅមីសុខលីមនឹងមីនឹងវាស្រលាញ់គ្នាក្មួយយកមករៀបនៅឯផ្ទះហើយក៏យកមករៀបនៅនឹងផ្ទះនឹងមីនឹងណាស់!

ក៖ ចាស!

ខ៖ ហើយនៅសល់ប៉ុន្មាននឹងឯងមិនទាន់មានគូនឹងគេទេនៅមិនទាន់ប្តីប្រពន្ធ(សើច)!

ក៖ ហើយអ៊ុំគិតយ៉ាងម៉េចចំពោះពួកគាត់ដែរអ៊ុំៗមានគំរោងមានអីសំរាប់ពួកគាត់ទៅថ្ងៃអនាគត់ដែរឬទេ?

ខ៖ ហ៊ើយ ក្មួយហើយមិនដឹងថាគំរោងអីទេនេះបើយើងវាក្រនឹងណាស់បើយើងវាអត់ណាស់(សើច)
ដឹងគំរោងអីចាំមើលតែបុណ្យសំណាងរបស់គេទៅគេរៀនសូត្រនេះឯងបានគេកើតបានអីធ្វើអីកើតរកអីបាន!

ក៖ (សើច)!

ខ៖ មានតែអញ្ចឹងទេ!

ក៖ ចាសៗអ៊ុំ ហើយអ៊ុំសព្វថ្ងៃមានមុខរបរជាអីដែរ?

ខ៖ មុខរបរខ្ញុំតែធ្វើស្រែនឹងក្មួយគ្មានមុខរបរអីពីដើមទៅដូចថាមានកំលាំងអញ្ចឹងទៅយើងលក់ដូរអីចឹងទៅខ្លះទៅណាស់ដល់ពេលឥលូវនឹងទៅមានតែធ្វើស្រែតែមួយមុខនឹង(សំលេងក្អក) ចិញ្ចឹមមាន់ទាចឹងទៅ(សើច)!

កៈ ចាស ហើយធ្វើស្រែធ្វើពីម៉ោងប៉ុន្មានទៅម៉ោងប៉ុន្មានទៅអ៊ុំធ្វើស្រូវប្រាំងឬក៏ស្រូវវស្សាដែរ?

ខៈ ខ្ញុំធ្វើតែស្រូវវស្សាទេ គ្មានម៉ោងទេធ្វើនឹងឯងធ្វើក្នុងមួយរដូវនឹងមួយរដូវស្រូវវស្សានឹងណាស់ប្រហែលជាមួយខែអីនឹងតែមិនដល់មួយខែទេរួចហើយ!

កៈ ចឹងហ៎អ៊ុំ?

ខៈ នឹងឯង!

កៈ អ៊ឹម! ហើយទៅនៅពេលដែលយើងប្រមូលផងម្តងៗបានប៉ុន្មានដែរអ៊ុំ?

ខៈ បានមួយគ្រប់គ្រាន់បានគ្រប់ហូបអីដែរណា!

កៈ ចាស!

ខៈ ចឹងឯង ហើយបើវាសល់វាសល់ទេបានមួយគ្រប់!

កៈ ចុះអ៊ុំអត់មានមុខរបរអីក្រៅតែពីធ្វើស្រែនឹងទេហ៎?

ខៈ ខ្ញុំធ្វើតែស្រែនឹង....

កៈ ហើយនឹងចិញ្ចឹមសត្វអីនឹងទៅ?

ខៈ នឹងឯងខ្ញុំមានចិញ្ចឹមគោចិញ្ចឹមអីទៅ!

កៈ អ៊ុំមានចិញ្ចឹមមាន់ដែរឬទេ?

ខៈ នឹងហើយចិញ្ចឹមមាន់ទាចឹងទៅ!

កៈ ចាស(សើច) ហើយអឺ...ចំពោះអ៊ុំប្រុសវិញគាត់មានមុខរបរជាអីដែរ?

ខៈ ចិញ្ចឹមតែគោនឹងឯងក្មួយ ធ្វើស្រែដូចតែគ្នានឹងឯងអត់មានមុខរបរអីទេ!

កៈ ជួយគ្នាទៅ!

ខៈ នឹងឯង(សើច)!

កៈ បានចិញ្ចឹមគោឡើងច្រើនអ៊ុំ?

ខៈ (សើច) គោមានបួនដប់ក្បាលដែរ មានកូនតូចខ្លះមេខ្លះចឹងទៅណា!

កៈ ចាសហើយអ៊ុំទាក់ទងជាមួយនឹងអ៊ុំកាលនៅនឹងជំនាន់ប៉ុលពតវិញគេជំលៀសអ៊ុំទៅនៅឯណាដែរ?

ខៈ ទៅនៅកាលនឹងឯងទៅនៅនឹងត្រពាំងព្រីងណាស់ ស្គាល់ដែរទេក្មួយ? ត្រពាំងព្រីងទក់ល្អក់យើងនេះណាស់ អេ...មិនមែនចង្អុលត្រង់នេះទេត្រង់ភ្នំពេញទេ(សើច)!

កៈ (សើច) ទៅនៅនឹងឯងហើយកាលនឹងឯងនៅពេលដែលគេជំលៀសនឹងឯងអត់ណាស់ក្មួយហើយ រកតែអំបិលហូបក៏មិនបានដែរជំនាន់នឹងនោះអត់មានអំបិលហូបទេ ទៅនាំគ្នាជីកដីអាដីជំបូកដីប្រាំអីនឹងយកមកស្ងោរទៅ ដល់ពេលស្ងោរចឹងទៅស្ងោរច្រើនដងណាស់ទំរាំនឹងបានចេញអំបិលណាស់(សំលេងរំខានពីខាងក្រៅ) ក្រាមៗមកនឹងឯងក៏កើតជាអំបិលទៅ!

កៈ អឺម....ចាស!

ខៈ នឹងឯង!

កៈ គេជំលៀសអ៊ុំនឹងក្រុមគ្រួសារទៅជាមួយគ្នាឬក៏យ៉ាងណាអ៊ុំកាលនឹង?

ខៈ ទៅទាំងអស់គ្នានឹងឯងក្មួយ មួយគ្រួសារទៅនឹង!

កៈ ហើយទៅគេអោយអ៊ុំរស់នៅជុំគ្នាដែរឬទេអ៊ុំ?

ខៈ គេៗអោយយើងនៅជុំគ្នាទេកាលនឹងណាស់ដល់ពេលបានប៉ុន្មានទេប្រហែលជាមួយឆ្នាំអីដឹងលោកតាខ្ញុំអីនឹងគាត់ក៏ខូចនៅនឹងឯង(លោកតារបស់គាត់បានស្លាប់) ទៅក៏គេអោយយើងត្រឡប់មកវិញណាស់កាលនឹងនោះ!

កៈ ចាសអឺម ហើយចុះកាលនឹងគេប្រើអ៊ុំអោយធ្វើអីគេខ្លះដែរអ៊ុំកាលនឹង?

ខៈ កាលនឹងខ្ញុំកុមាររនៅឡើយទេក្មួយ គេមិនទាន់ធ្វើអីទេកាលនឹងណាស់ជំនាន់ៗនឹងណាស់ នៅកុមាររទេ នៅកុមារនឹងគេៗដូចមុនដំបូងគេជំលៀសយើងទៅដល់តែគេជំលៀសយើងទៅនឹងឯងអោយយើងទៅលត់ដំអត់ឃ្លានចឹងឯងទៅគេយកយើងមកវិញចូលជាសហាករណ៍ដល់ពេលដែលចូ

លជាសហាករណ៍អញ្ចឹងឯងទៅបានទៅលត់ជំម្តងទៀត សុីបបរពោតលាយជំឡូង ចឹងឯងទៅណាស់ហើយទៅគេអោយយើងចូលជាមិត្តនារីហើយកាលនឹងនោះ!

ក៖ អឹម!

ខ៖ ហើយមិត្តនារីនឹងឯងយើងអាយុប៉ុន្មានប្រហែល១០ឆ្នាំ អើ...ប្រហែលអីអាយុបាន១៤ឆ្នាំ ១៥ឆ្នាំអីនឹងអោយៗយើងរៀងជំទើរនឹងណាស់ទៅគេអោយយើងទៅដកស្ទូងៗនៅនឹងភូមិហើយនឹងឯងគេអោយយើងនឹងហើយទៅទៀតហើយទៅលើនឹងឯងទៅនឹងក្លុងហើយក្លុងនឹងឯងគេហៅទំនប់មួយមករាណាស់!

ក៖ ចាសអុឺ!

ខ៖ (ក្រហែម) ទៅគេអោយយើងនឹងឯងរែកដីៗចឹងឯងទៅត្រឡប់មកវិញចឹងទៅគេបបរអោយយើងសុីហើយប្រហុកបបរប្រហុកទៅគេធ្វើប្រហុកអោយសុីចឹងឯងណាស់!

ក៖ ចាសអុឺ!

ខ៖ ហើយទៅដល់ចឹងដល់ពេលដែលយើងឃ្លានខ្លាំងពេកណាស់យើងរែកដីចឹងទៅយើងឃ្លានខ្លាំងពេកនឹងយើងធ្វើជានោមជាជុះអីចឹងទៅហើយទៅ(សើច)!

ក៖ (សើច)!

ខ៖ ទៅបួតអាវែងនែ...ស្អីអាជូរៗណាស់ស្លឹកថ្មីងចឹងទៅយកមកសុីមក!

ក៖ អឹម!

ខ៖ ទៅឆាប់មករែកដីវិញបើមិនរែកឯណាបើកាប់ដី២ម៉ែត្រគីបគេសុទ្ធតែវាស់ម៉ែត្រចែកគ្នាមួយៗព្រឹកចឹងឯងអោយបានមួយម៉ែត្រគីបហើយដល់ទៅល្ងាចចឹងទៅគេអោយយើងជីកបានមួយម៉ែត្រគីបដែរ ហើយដូចថាកាលនឹងយើងវានៅតូចៗចឹងណាស់រែកដី....

ក៖ ហើយទៅកាលនឹងគេយកអុំទៅណាដែរអុឺ?

ខ៖ កាលនឹងអាយុ១៥ឆ្នាំ!

ក៖ អូ....

ខ៖ គេអោយយើងរែកដី!

ក៖ កំពុងពេញកំលាំងន៏អ៊ុំ?

ខ៖ ហើយ ពេញកំលាំងឯណានឹកម៉ែចង់ងាប់(សើច)!

ក៖ (សើច)!

ខ៖ គ្រុនចង់ងាប់(សើច)!

ក៖ ចឹងកាលនឹងអ៊ុំធ្លាប់ឈឺដែរន៏អ៊ុំ?

ខ៖ ឈឺជំនាន់ប៉ុលពតចាញ់(សំលេងមាន់រងាវ) កាលនឹងដែលស្គាល់មកពីណាប្លុងអីនឹងខ្ញុំមិនស្គាល់ទេ!

ក៖ គេមានធ្លាប់អោយថ្នាំឬក៏អោយមន្ទីរពេទ្យព្យាបាលអ៊ុំដែរឬទេ?

ខ៖ ហើយគ្មានទេ កាលនឹងដូចជាដូចថាមិនត្រូវអស់ជីវិតអីចឹងណាស់ អាយុយើងមិនទាន់អស់មិនស្លាប់ចឹងទៅណាស់ អាថ្នាំ(សំលេងមាន់រងាវ) អាគេសូន្យខ្មៅៗនឹងណាស់ទៅគេអោយយើងលេបទៅ តែលេបទៅនឹងមិនចូលផងទៅទេ ទំពារទៅវាពេញម៉ាមាត់នឹង!

ក៖ ចាស!

ខ៖ (សំលេងមាន់រងាវ) មិនទៅដូចថ្នាំយើងសព្វថ្ងៃនឹងឯណាក្មួយហើយ!

ក៖ ចាស ចុះកាលនៅជំនាន់នឹងគេមានធ្លាប់ដែលធ្វើបាបអ៊ុំដែរឬទេអ៊ុំ?

ខ៖ គេធ្លាប់តែធ្វើបាបយើងតែអោយយើងស៊ីបបរស៊ីអីនឹង ហើយគេកំញើញយើង(សំលេងមាន់រងាវ) ដូចថាយើងសសរអីនឹងគេកំញើញយើងគេថាយើងនឹងពូជចិនពូជយួនទៅណាស់ទៅគេប្រុងយកទៅស្លាប់ចោលស្លាប់អីចឹងទៅណាស់ហើយទៅយើង(សំលេងមាន់រងាវ) ឈឺក៏ដោយជាក៏ដោយក៏ខំប្រឹងរែកដីនឹងទៅ(សើច)!

ក៖ ចាសអ៊ុំ ចឹងកាលនឹងនៅក្នុងជំនាន់នឹងឪពុកម្តាយរបស់អ៊ុំគាត់ធ្វើអីដែរអ៊ុំ?

ខ៖ គាត់នៅនឹង(សំលេងមាន់រងាវ) នឹងផ្ទះឯងគាត់ចាស់ហើយចឹងគេអោយគាត់កាប់ជីកើបជីអីចឹងទៅ

ហើយគេអោយគាត់រវៃអាកាបាសយើងនឹងជ្រលក់ទៅកាត់ធ្វើសំពត់ធ្វើអីចឹងទៅ(សំលេងមាន ន់រងាវ)!

កៈ ចាស ប៉ុន្តែមុននឹងចូលទៅដល់ជំនាន់ប៉ុលពតឪពុកម្តាយរបស់អ៊ុំមានមុខរបរធ្វើអីគេឬក៏រកស៊ីអីគេដែរ អ៊ុំកាលនឹង?

ខៈ អត់ទេខ្ញុំកសិករតែម៉ង!

កៈ ចាស!

ខៈ នៅនឹងកាលណោះ....

ខៈ ព្រោះអីលឺថាកាលជំនាន់ប៉ុលពតនឹងដូចថាបើយើងមានឪពុកម្តាយគាត់មានមុខរបរដូចថាម ន្ត្រីរាជការអីនឹងគេរិតបន្តឹងណាស់!

កៈ នឹងឯងធ្វើទាហានធ្វើប៉ូលីសសអីនឹងអត់បានទេកាលនឹងនៅហ៎ បើសិនជាយើងអោយតែលឺធ្វើទាហានធ្វើប៉ូលីសអីគេយកយើងទៅវ៉ៃចោលវ៉ៃអីនឹងណាស់!

កៈ ចាសគេយកយើងទៅកសាង!

ខៈ មិនមែនយកយើងទៅកសាងទេ(សើច)!

កៈ (សើច) គេយកទៅរៀនសូត្រ!

ខៈ នឹងឯង ពេលដែលគេយកទៅរៀនសូត្រនឹងបាត់ខ្លួនហើយ(សើច)!

កៈ ចាសហើយអឺ...កាលជំនាន់នឹងអ៊ុំដូចជាគេបានប្រើអ៊ុំអោយធ្វើការច្រើនចឹងពេលនឹងអ៊ុំចង់អោ យដាច់ភ្លាមៗទេនៅក្នុងចិត្តកាលនឹងមានដែលគិតចឹងដែរឬទេ?

ខៈ ហើយនៅក្នុងចិត្តពេលនឹងហ៎ នឹកម៉ែស្រែកយំយប់ៗឡើងនឹងយំរាល់តែយប់ដែលឃ្លាតពីម៉ែណាស់បន់អោយតែទៅជួបម៉ែទេ បន់អោយតែដាច់កាលនឹងឯងនឹកឃើញថាហើយវរៗបើអោយតែចេះឯងច្បាស់ជាស្លាប់ហើយ មិនរស់ទេ(សំលេងរំខានពីខាងក្រៅ) វែកដីតែរហូតនឹង!

កៈ ចាសអ៊ុំ ហើយចុះអ៊ុំមាននឹកដល់បងប្អូនរបស់អ៊ុំដែរឬទេ?

ខៈ នឹក កាលនឹងនៅបែកគ្នា!

កៈ អឺម! បងប្អូនរបស់អ៊ុំប៉ុន្មាននាក់ហើយអ៊ុំ?

ខៈ កាលនឹងជំនាន់នោះមើលបីនាក់ មើល ណៃអៀក មីក្វយ ហើយនឹងខ្ញុំនឹងហើយបងប្រុសមួយទៀតទាំងអស់បួននាក់ប៉ុន្តែបងៗរបស់ខ្ញុំច្រើនណាស់ប៉ុន្តែគាត់មានប្តីមានប្រពន្ធអស់ទៅណាស់គាត់នឹងផ្ទះគាត់ធ្វើការនៅនឹងផ្ទះធ្វើការនៅនឹងផ្ទះគេអោយស្ទូងដកអញ្ចឹងឯងដល់ពេលតែខ្ញុំទេដែរនៅលីវណាស់ដល់ពេលបងប្រុសខ្ញុំនឹងឈ្មោះចូយមួយលីវ ណៃអៀកមួយ ហើយនឹងខ្ញុំនេះមួយ ហើយនឹងប្អូនស្រីរបស់ខ្ញុំនឹងឯងបែកគ្នាទាំងអស់អត់មាននៅកងចល័តអីជាមួយគ្នាទេណាស់ជំនាន់នោះណាស់!

កៈ ចាសអ៊ុំស្រី អូយ! ជំនាន់នោះពិបាកណាស់អ៊ុំគេប្រើអ៊ុំធ្វើការងារច្រើនហើយទៅអ៊ុំមានធ្លាប់ឃើញអាពតយកមនុស្សទៅសំលាប់ចោលដែរឬទេ?

ខៈ អឺម ឃើញក្អួយអើយប៉ុន្តែនៅកាលនឹងយើងអត់ហ៊ានទេ ហើយដល់ពេលគេយកមនុស្សអីចឹងនឹងដូចជាពួកចាមអីចឹងនឹង នែ...ដល់ពេលយើងហូបបាយហូបបបរអីចឹងប្រាប់គ្នាថាទៅធ្វើត្រីប្រហុកចឹងទៅយកទៅបាត់ទៅៗមនុស្សនឹងចឹងឯងណាស់!

កៈ អឺម!

ខៈ
អោយគ្នាទៅធ្វើនេះទៅធ្វើនោះហើយបញ្ជូនទៅនឹងថាអោយគ្នានឹងទៅនៅនឹងស្រុកអីវិញចឹងទៅណាស់គ្នារៀបចំឥវ៉ែតវ៉ាន់នឹងឯងដាក់ទៅនឹងរទេះនឹងឯងពេញមួយរទេះនឹងឯងគ្នាត្រេកអរណាស់ដើរលាយើងណាស់ស្មានថាបានទៅស្រុក!

កៈ អឺម!

ខៈ ទៅគេយកគ្នាទៅវ៉ៃចោលបាត់ទៅ!

កៈ ខំតែដាក់ឥវ៉ាន់យកទៅនឹង!

កៈ ហើយ....នឹងឯងរៀបចំតវែតវ៉ាន់ទៅតែប៉ុន្មានមួយភ្លែតនឹងឯងតវ៉ាន់ត្រូវត្រឡប់មកវិញបាត់តែមនុស្ស(សើច)!

កៈ អឺម! ហើយកាលនឹងអ៊ុំភ័យដែរឬទេនៅពេលដែលបានឃើញចឹង?

ខៈ ភ័យក្មួយ ខ្លាចគេចង់ងាប់នឹងមិនមានហ៊ានកុំរើកទេគេប្រើអោយទៅណាយើងទៅនឹងតែចឹងរហូតនឹង!

កៈ ចាសគេធ្វើចឹងដើម្បីអោយយើងបាក់ស្បាតណាស់អ៊ុំ!

ខៈ នឹងហើយ អោយយើងបាក់អោយយើងខំប្រឹងធ្វើនឹងណាស់ក្មួយទាំងឈឺទាំងជានឹងណាស់មិនអោយយើងឈប់ទេ!

កៈ ចាស!

ខៈ អោយតែពួកអ្នកថ្មីសុទ្ធតែបញ្ជូនគ្នានឹងទៅស្រុកហើយ!

កៈ អឺម!

ខៈ បញ្ជូនគ្នាទៅស្រុកអីវាៗយកគ្នាទៅវ៉ៃចោលនឹង!

កៈ ចាសចុះបើកាលនឹងគេធ្វើបាបចឹងតាំងពីគេប្រើយើងហើយនឹងគេអោយអាហារយើងតិចតួចអីចឹងអ៊ុំរបៀបធ្លាប់លួចអីគេដើម្បីយកមកបំពេញក្រពះខ្លួនឯងដែរឬទេកាលនឹង?

ខៈ ទៅលួចតែទៅស៊ីស្លឹកថ្នឹងនឹងឯង!

កៈ តែប៉ុន្នឹងទេន៍អ៊ុំ?

ខៈ ប៉ុណ្ណឹងឯងអត់ហ៊ានទៅយកអីគេទេ!

កៈ ចាសចុះគេដែរទាន់ដែរឬទេអ៊ុំ?

ខៈ អូ...គេមិនទាន់ទេយើងៗដូចថា.....

កៈ យើងពូកែលួច(សើច)!

ខ៖ ដូចថាយើងប្រាប់គេ(សើច)!

ក៖ (សើច)!

ខ៖ ប្រាប់គេថាបងហើយអោយខ្ញុំសុំទៅបត់ជើងមួយភ្លែតចឹងណាស់!

ក៖ ចាស!

ខ៖ ទៅលួចស្លឹកថ្នឹងនឹងមកចឹងទៅយើងយកមកដាក់នៅនឹងហោប៉ៅយើងនឹងទៅ(សើច)!

ក៖ (សើច)!

ខ៖ ដល់ពេលហេវខ្លាំងស៊ីអាស្លឹកថ្នឹងនឹងឯងទៅដាក់...លួចអំបិលគេនឹងបន្តិចដល់ពេលដែលយើងទៅហូបបាយអីចឹងណាស់ទៅយើងសុំអំបិលគេនឹងមក...

ក៖ អឹម!

ខ៖ យកមកខ្ចប់ទុកទៅដល់ពេលធ្វើការប្រាប់គេ(សំលេងរំខានពីខាងក្រៅ) សុំគេទៅបត់ជើងបត់ដៃអញ្ចឹងទៅ(សំលេងរំខានពីខាងក្រោ) ទៅលួចអាស្លឹងថ្នឹងនឹងឯងយកមកស៊ីទៅ(សើច)!

ក៖ ចាស!

ខ៖ ហើយជំនាន់អាលាប់នោះដល់ក៏ហើយ!

ក៖ (សើច) ចាសអ៊ុំ(សើច)!

ខ៖ (សើច)!

ក៖ នឹងហើយកាលនឹងពិបាកពេកចឹងភាគច្រើនចឹងអ៊ុំអី...ដូចថាឃ្លានខ្លាំងពេកចឹងទៅ...

ខ៖ ឃ្លានពេកណាស់ក្មួយ!

ក៖ ក៏ទៅលួចអីបន្តិចបន្តួចដើម្បីនឹងយកមកបំពេញក្រពះរបស់ខ្លួនឯងណាស់ គេអោយបបរអីនឹងហូបម៉េចនឹងបានឆ្អែតទៅ!

ខ៖ ឆ្អែតមិនឆ្អែតនឹងក៏អត់ទៅទ្រាំអត់ទ្រាំឃ្លាននឹងទៅ!

ក៖ នៅសម័យនឹងមើលទៅពិបាកខ្លាំង!

ខ៖ ដូចយើងវាខ្លាចគេពេកណាស់ក្មួយ!

ក៖ ចាស!

ខ៖ បើខ្លះដូចតែថាគេបងគេអីចឹងទៅគេធ្វើខាងរោងបាយរោងអីចឹងទៅណាស់ទៅគេបាយបងនឹង ឯងលួចហុចអីនៅពេលយប់ព្រលប់អីចឹងណាស់ទៅគេបានហូបទៅយើងអត់មានបងប្អូននឹងគេអត់ហើយស៊ីស្លឹកថ្នឹងនឹង(សើច)!

ក៖ (សើច)!

ខ៖ (ដកដង្ហើមធំ)!

ក៖ ចុះកាលសម័យជំនាន់នឹងអ៊ុំមានការចងចាំនូវទិដ្ឋភាពអីខ្លាំងជាងគេដែរអ៊ុំកាលនឹង?

ខ៖ យ៉ូយ! មានចាំអីហ្នសពីអាគេយកមនុស្សទៅវ៉ៃចោលទេ ស្រាវខ្លួនណាស់លោកហើយគ្រាន់តែឃើញពូកវាដូចថាអ្នកថ្មីអីអញ្ចឹងវាដូចស្មោះត្រង់អីនឹងគ្នាស្រលាញ់គ្នាធ្វើការៗស្រាប់តែហៅគ្នាមកចឹងឯងទៅផ្ទះ រៀបចំឥវ៉ាន់ទៅៗផ្ទះវាថាចឹងណាស់ហើយទៅយកគ្នាទៅវ៉ៃចោលដឹងៗវ៉ៃដឹងថាគេយកទៅវ៉ៃចោលចឹង ឯណោះដឹងខ្លួនហើយអ្នកដែលថ្មីនឹងណាស់!

ក៖ ចាស!

ខ៖ ចឹងហើយដើរសំពះទឹកភ្នែកហើយប៉ុន្តែម្នាក់ៗគ្រាន់តែលួចមើលមុខគ្នាទេ ទៅមករោងវិញអោយកញ្ច្រោលបានថាអើយលោកហើយលោក កុំអោយមានគេយកទៅវ៉ៃចោលអីលោកអើយអោយទៅផ្ទះមែនទៅ ចឹងណាស់បើយើងធ្លាប់នឹងហើយបើមីមួយនោះមីនឹងគេថាគ្នាយួនណាស់ជំនាន់នោះណាស់ទៅនៅកងជាមួយគ្នាទៅគ្នាដើរលាគ្នា ណៃអួយអើយអាញ់លាសិនហើយ គេថាម៉ែអាញ់គាត់ចុកពោះរួចអាមួយនឹងហើយកាំបិតប្រគាក់នេះប្រវែងនេះ ស៊កនឹងកង់ទៅឱបគ្នាយកទៅបាត់ទៅ បាត់ទៅក៏បាត់ឈឹងទៅ ដំណឹងមកវ៉ៃគ្នាចោលបាត់ហ៊ឹមជំនាន់នោះលោកអើយ!

ក៖ អ៊ឹម! ចាសកំពុងពិបាកហើយទាំងអី....ការស្នាក់នៅការស្លៀកពាក់ការហូបចុកទាំងអស់នឹងគឺពិបាកទាំងអស់ម៉ង ហើយទៅនៅបែកគ្នា....

ខ៖ បើថាខោវិញសុទ្ធតែបំណាស់ពពើកអស់ក្រមាប៉ះៗទៅជ្រុះអស់ទៅទំរាំនឹងគេចែកក្បាលទទេរនឹងទៅមានតែអាម្ចូកស្លឹកត្នោតយើងដែរ យើងធ្លាប់ដេរណាស់នោះដូចម្ចូករបស់មីអូននោះនៅខាងនោះដេរកើតនឹងក៏ពាក់តែម្ចូកនឹងឯងទៅហើយនឹងអាសំពត់ខ្មៅព័តពែងៗនឹងទៅរែកដី ហើយវិះតែនឹងផ្កាប់មុខ(សំលេងរំខានពីខាងក្រៅ) គេអោយយើងស្លៀក(សើច)!

ក៖ (សើច)!

ខ៖ គេអោយយើងស្លៀកៗសំពត់!

ក៖ ចាសអ៊ុំអឹម...ហើយកាលនឹងអ៊ុំបានរបបដូចជាគេអោយអ៊ុំស្បែកជើងគេអោយអ៊ុំដូចជាខោអាវខោអីនឹងគេអោយក្នុងរយពេលប៉ុន្មាន?

ខ៖ នឹងឯង ដូចថាខោអាវស្បែកជើងអីនឹងឯងដូចតែនៅក្នុងជំនាន់ប៉ុលពតនឹងឯងដូចគេអោយតែពីរដងទេណាស់ អោយតែពីរដងតែស្បែកជើង....

ក៖ បីឆ្នាំប្រាំបីខែបានតែពីរកំប្លេទេហ៍អ៊ុំ?

ខ៖ បានៗស្បែកជើងពីរគូហើយនឹងខោអាវពីរដងនឹងឯងសំពត់នឹង ហើយ....

ក៖ ហើយខោអាវនឹងគេជាអ្នកចែកហ្អែសអ៊ុំមិនមែនខោអាវយើងយកទៅជ្រលក់ថ្នាំខ្មៅទេហ៍អ៊ុំ?

ខ៖ ជ្រលក់!

ក៖ ខោអាវយើងនឹងហ៍អ៊ុំ?

ខ៖ នឹងឯងជ្រលក់ព័ណខ្មៅៗនឹង!

ក៖ ចាស ហើយចុះទ្រព្យរបស់យើងដែលបានពីកាលសម័យគេជំលៀសទៅពីផ្ទះចាស់ណាស់អ៊ុំយករបស់អីទាំងអស់នឹងដូចជាគេមិនអោយយើងយកទៅទាំងអស់ទេហ៍អ៊ុំ?

ខ៖ គេមិនអោយយើងទេ បើយើងកាលណោះម៉ែរបស់ខ្ញុំគាត់នៅនឹងផ្ទះចឹងទៅបានចានបានស្លាបព្រាចានឆ្នាំងអីនឹងស៊ី

មិននឹងគ្រប់គ្នាផងទៅទេ
បេះអាស្លឹកឈូកនឹងឯងស៊ីកាលដែលការខ្ញុំនឹងឯងស៊ីស្លឹកឈូកតើ(សើច)!

ក៖ (សើច)!

ខ៖ (សើច) ហើយ ហើយទៅចងដៃនឹងអង្ករ(សើច) កាលនឹងណាស់ការទៅម្នាក់ៗមិនមែនថង់ដូចជាយើងសព្វថ្ងៃនឹងទេណារួចហើយក៏ដាក់នឹងថ្នក់ក្រមាចឹងទៅ(សើច)!

ក៖ ចាសអុំ!

ខ៖ យកមកដាក់ចងដៃចឹងទៅដាក់អង្ករនឹងតៅនឹងកញ្ជើរអីចឹងទៅណាស់(សំលេងទូរស័ព្ទរោទិ៍)!

ក៖ ចាសអុំស្រី កាលនឹងបើទោះបីជាកញ្ចាស់ៗអីតែក៏វាមានតំលៃណាស់អុំព្រោះកាលនឹងយើងទើបតែដាច់ពីជំនាន់ប៉ុលពតចឹងណាស់អុំ!

ខ៖ ចាសនឹងឯង!

ក៖ រកមិនបានទេម្នាក់ៗកាលនឹងណាស់អុំ?

ខ៖ ចាសនឹងហើយ!

ក៖ ចាស!

ខ៖ បានតែអង្ករប៉ុណ្ណឹងនឹងមិនបាច់ទេ!

ក៖ (សើច)!

ខ៖ (សើច) បានហូបបន្តទៅទៀតណាស់(សើច)!

ក៖ (សើច) ចាសត្រូវហើយអុំ!

ខ៖ ប៉ុន្តែបន្តទៅទៀតដល់វេនគេការម្តងចឹងទៅយើងយកទៅ....

ក៖ អោយគេវិញទៅ....

ខ៖ អោយគេទៅវិញទៅចឹងឯងណាស់!

កៈ អឺ....អ៊ុំស្រីខ្ញុំចង់ដឹងថាមុខរបររបស់អ៊ុំស្រីកាលពីមុនមកណាស់ សល់កាលពីជំនាន់ដូចជានៅសល់ពីកាលដែលមិនទាន់នឹងបានចូលអាពតទេ ដល់ពេលចប់អាពតទៅគេមិនជំលៀសអ៊ុំទៅហើយនៅពេលនឹងអ៊ុំមិនត្រូវយកឥវ៉ាន់ទៅក្នុងអាពតនឹងហើយទៅគេមានដករឹបអូសយកឥវ៉ាន់របស់អ៊ុំស្រីទៅអស់ដែរឬទេកាលនឹងអ៊ុំ? ហើយអ៊ុំមាននៅសល់អីនៅក្នុងខ្លួនដែរឬទេ?

ខៈ អឺម....កាលនឹងឯងគោក្របីអីនឹងដល់ពេលដែលយើងមកពីជំលៀសវិញ(សំលេងរំខានពីខាងក្រៅ) នឹងមកចូលនៅក្នុងភូមិវិញនឹងត្រូវគេដកយកហើយគោក្របីអីនឹងណាស់ត្រូវគេដកយកអស់ហើយៗគេអោយយើងហូបបាយនៅតាមសហករណ៍នឹងហើយ!

កៈ ចាស អឺម....ហើយទៅកេរ្តិ៍កាលដែលនៅសល់ពីជំនាន់ដើមអីនឹងគឺអត់មាននៅសល់អីទេន៍អ៊ុំ(សំលេងរំខានពីខាងក្រៅ)!

ខៈ ហើយគ្មាននៅសល់អីទេ អត់មាននៅសល់អីទេដល់ពេលយើងដាច់អីចឹងឯងទៅយើងនាំគ្នារត់ទៅចាប់គោដែលគេខ្មៀលម្តុំអញ្ចឹងឯងទៅនៅក្នុងព្រៃនឹងនាំគ្នាទាក់គោទំរាំនឹងបានមួយក្បាលយកចិញ្ចឹមណាស់!

កៈ អឺម ចាស!

ខៈ ចឹងឯង!

កៈ ចាសហើយទៅអ៊ុំកាលពីជំនាន់មុនពេលដែលអ៊ុំមិនទាន់បានចូលទៅនៅក្នុងជំនាន់អាពតនឹងនៅក្នុងសម័យលន់នលហ្អែសអ៊ុំ?

ខៈ នឹងហើយ!

កៈ ចាសហើយចុះកាលសម័យអ៊ុំមាននៅចាំអីគេខ្លះដែរឬទេអ៊ុំ?

ខៈ ហើយក្មួយអើយខ្ញុំអត់ចាំទេកាលនឹងខ្ញុំនៅតូចពេកណាស់ខ្ញុំៗនៅតូចពេកកាលនឹងឯងវាអត់ទាន់ចាំថាស្អីអោយប្រាកដណាស់ថាជំនាន់អឺ....អ៊ុនតាក់ហ៊ីកាលនឹងនោះ អ៏...ម៉េចទេជំនាន់អីទេ(សំលេងរំខានពីខាងក្រៅ) កាលនឹងឯងណាស់!

គ៖ ជំនាន់លន់នល(សំលេងមនុស្សពីខាងក្រៅ)!

ខ៖ លន់នលអ៊ុនតាក់អីនឹងហើយ គ្រាន់តែដឹងកាលជំនាន់នឹងឯងយើងវាមិនដឹងថាជាជំនានន់លន់នលនឹងយើងកាលនឹងវាតូចៗ ចឹងដើរលក់អី...លត់ណាស់កាលនឹងជាមួយបង(សំលេងរំខានពីខាងក្រៅ) យើងវាមិនដឹងច្បាស់ណាស់កាលនឹង!

ក៖ អឹម...ចាសនៅពេលនឹងអ៊ុំអត់បានចាំទិដ្ឋភាពអីច្រើនទេន៍អ៊ុំព្រោះកាលនឹងនៅតូចហើយអ៊ុំគ្រាន់តែនៅចងចាំថាអ៊ុំកាលនឹងអ៊ុំលក់លត!

ខ៖ នឹងឯងកាលនឹងខ្ញុំនៅតូចៗដើរលក់លតហើយ(សំលេងរំខានពីខាងក្រៅ) បើឃើញថាពួកប៉ូលីសទាហានអីអញ្ចឹងឯង(សំលេងរំខាងពីខាងក្រៅ) អាពួកប៉ូលីសទាហានគេនឹ ងឯងចូលមកនៅក្នុងស្រុកក្នុងភូមិនឹងឯងប៉ុន្តែយើងវានៅមិនទាន់ដឹងថាវាម៉េចរាក់ជ្រៅណាស់!

ក៖ ចាស!

ខ៖ ចឹងឯង!

ក៖ កាលនឹងអ៊ុំលក់លតនឹងដោយសារតែឪពុកម្តាយគាត់ជាអ្នកបង្រៀនអ៊ុំធ្វើឬក៏យ៉ាងណាដែរ?

ខ៖ ម្តាយអ្នកធ្វើទៅហើយកូនជាអ្នកដើរលក់ចឹងទៅ នឹងឯង!

ក៖ អូ....ធ្វើលតដាក់ទឹកស្ករនឹងហ៎អ៊ុំ?

ខ៖ នឹងហើយ!

ក៖ អ៊ុំចេះធ្វើនំលតន៍អ៊ុំ?

ខ៖ នឹងឯង!

ក៖ កាលនៅនឹងលក់មួយនឹងប៉ុន្មានដែរអ៊ុំ? មួយចាននឹងប៉ុន្មាន?

ខ៖ លតមួយចានកាលណោះនឹងឯងនោះយើងកាលជំនាន់នឹងឯង ហើយខ្ញុំមិនជាសូវចាំលុយទេណាស់ដូចមួយរៀលពីររៀលមួយចានអីចឹងណាស់!

កៈ ចាស!

ខៈ មួយចានចឹងឯងទៅពីររយ អេ! មិនដល់អឺ...ពីររៀលអីចឹងណាស់នឹងហើយមិនមែនចាយរយដូចឥលូវនឹងអី!

កៈ ឥលូវនឹងរបស់ថ្លៃៗ(សើច)!

ខៈ នឹងហើយ!

កៈ កាលនឹងមានលុយតិចតួចអីអាចរកមុខរបរអីបាន(សំលេងរំខានពីខាងក្រៅ)!

ខៈ នឹងឯង!

កៈ កាលនឹងគេចាយដូចជា(សំលេងរំខានពីខាងក្រៅ) ដូចតាមខ្ញុំដឹងគេចាយកាក់ដែរហ្អែសអ៊ុំ?(សំលេងរំខានពីខាងក្រៅ) លុយកាក់ណាស់អ៊ុំ?

ខៈ នឹងហើយកាលនឹងខ្ញុំអត់ទាន់ដឹងដែរមិនៗ កាលដែលខ្ញុំទាន់ៗតែលុយៗក្រដាសនឹង ចាសលុយក្រដាសនឹងខ្ញុំទាន់(សំលេងរំខានពីខាងក្រៅ)!

កៈ អូ...ចាសអ៊ុំ! ហើយអឺ...ឪពុកម្ដាយរបស់អ៊ុំមានធ្លាប់និយាយប្រាប់អ៊ុំពីរឿងកាលពីសម័យមុនៗគេចាយលុយអីៗប្រាប់មកដល់អ៊ុំដែរឬទេ?

កៈ គាត់មិនដែលនិយាយដែលទៅនិយាយ (សំលេងរំខានពីខាងក្រៅ) អេ...បើទោះជានិយាយក៏យើងវាមិនចាំណាស់ អឹម!

កៈ ចាស(សំលេងរំខានពីខាងក្រៅ)!

ខៈ គ្រាន់តែគាត់និយាយថាដូចថា(សំលេងរំខានពីខាងក្រៅ) ជំនាន់ឥស្សរៈអីចឹងឯងចេះតែលឺៗចឹងឯងចាំតែត្រង់កន្លែងឥស្សរៈនឹងឯងប៉ុន្តែមិនដឹងថាឥស្សរៈនឹងរបៀបម៉េចទេ(សើច)!

កៈ (សើច)!

ខៈ (សើច) ដឹងជាម៉េច(សើច) ចឹងណាស់ក្មួយ!

កៈ ចាសអ៊ុំ!

ខ៖ វាមិនដឹងរាក់ជ្រៅម៉េចទេ(សំលេងរំខានពីខាងក្រៅ)!

ក៖ អឺម....ចាសអ៊ុំស្រី ហើយនៅកាលនឹងអ៊ុំបានរៀងដល់ថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខ៖ (ក្អក) ហើយកាលនឹងឯងខ្ញុំនៅតូចពេកមិនៗទាន់បានរៀនទេកាលនឹង(សំលេងរំខានពីខាងក្រៅ) ហើយដល់ពេលដែរចូលរៀន វាដូចថាយើងវាក្រដែរណាក្មួយហើយវា...បើយើងរៀននឹងក៏បានដែរកាលនឹងបើក្មេងតល្ងវនឹង អាយុប្រាំ ប្រាំមួយឆ្នាំចូលរៀនបាន(សំលេងរំខានពីខាងងក្រៅ) ដូចខ្ញុំអីអាយុនឹងឯងប្រាំមួយ ប្រាំពីរឆ្នាំនឹងឯងបើសិនជាចូលរៀនក៏បានដែរ ប៉ុន្តែដល់ពេលកាលនឹងយើងវាអត់ចឹងទៅ(ពេលនឹងគ្រួសារក្រខ្សត់) យើងមានបានទៅចូលរៀនឯណាបើយើងរវល់តែដើរលក់អញ្ចឹងឯងណាស់!

ក៖ ចាសអ៊ុំស្រី!

ខ៖ ហើយយើងមិនទៅបានចេះអីនឹងគេ ដល់ពេលនៅជំនាន់ប៉ុលពតគេហៅដែលយើងនៅតូចៗចឹងឯងអោយរៀន ក ខ អីចឹងទៅគេអោយប្រកបអីចឹងទៅតិចទៅក៏គេហៅចូលកងនារីមិត្តនារីមិត្តអីឯណាឯណីបាត់ទៅ(សំលេងរំខានពីខាងក្រៅ) !

ក៖ អឺម!

ខ៖ ដែលយើងមានទៅចេះអីកាលនឹងនោះ(កាលជំនាន់នឹងគាត់អត់ចេះអក្សរទេ)!

ក៖ ចឹងអី...អ៊ុំអត់អាចអី...រាល់ថ្ងៃនឹងអ៊ុំអាចនឹងចេះអានចេះសរសេរចេះមើលអក្សរខ្មែរដាច់ដែរឬទេអ៊ុំ(សំលេងរំខានពីខាងក្រៅ)?

ក៖ ខ្ញុំមើលដាច់ដូចល្មមៗដែរទេ(សំលេងរំខានពីខាងក្រៅ) បើដូចថា(សំលេងផ្គេីព្រួស) ចង់ថាចេះដូចកូនរៀនអីចឹងឯងឃើញកូនប្រកបអីនឹងខ្ញុំទើបតែចេះនៅសម័យនេះដែរនឹង ចឹងដែរណាស់ក្មួយ(សើច)!

ក៖ អឺម! ចាសហើយអ៊ុំស្រីមានចេះភាសាអីផ្សេងដែរឬទេ ឬមួយក៏អត់ទេអ៊ុំ?

ខ៖ អត់មានចេះទេខ្ញុំគ្មានចេះភាសាអីទេ(សើច)!

កៈ ចាស ហើយចុះបងប្អូននៅក្រៅប្រទេសអ៊ុំមានដែរឬទេអ៊ុំ?

ខៈ អត់ទេ អត់មានទេៗខ្ញុំ(សំលេងរំខានពីខាងក្រៅ)!

កៈ អឺម....ចាសមានតែរស់នៅនឹងក្នុងស្រុកយើងន៍អ៊ុំ?

ខៈ នឹងហើយ(សំលេងរំខានពីខាងក្រៅ)!

កៈ
ចាសអ៊ុំកាលពេលអ៊ុំអឺ...សម័យដែរអ៊ុំការលើកមុនកាលឆ្នាំដែលក្រោយដាច់អាពតនឹងហើយណាស់(សំលេងរំខានពីខាងក្រៅ)
ពេលដែលបានដាច់អាពតហើយអ៊ុំរៀបការនឹងកាលនៅជំនាន់នឹងអ៊ុំមានដូចជាចែកធៀបការឬក៏ទៅប្រាប់មាត់និយាយម៉ង...

ខៈ (ក្អកហើយនឹងសើច)!

កៈ កាលនឹងទៅប្រាប់នឹងមាត់ទេន៍អ៊ុំ(ពេលទៅប្រាប់ការគេប្រាប់ដោយការអញ្ជើញនឹងមាត់គ្មានសំបុត្រអញ្ជើញទេ)?

ខៈ អឺម...គ្មានទេ(សំលេងរំខានពីខាងក្រៅ) គ្មានទៅមានធៀបការអីទេ កាលនឹងឯងម្តាយខ្ញុំនឹងឯងគាត់ដើរជំរាបគេចឹងទៅណាស់(ម្តាយរបស់គាត់ដើរអញ្ជើញភ្ញៀវការ)!

កៈ សរសេរសំបុត្រអី.....

ខៈ តែប៉ុណ្ណឹងឯងគ្មានសំបុត្រគ្មានអីទេ(សំលេងរំខានពីខាងក្រៅ) យើងគ្រាន់តែអញ្ជើញៗគេនឹងដែអញ្ចឹងទៅណាស់!

កៈ អូ....

ខៈ កាលណោះហ៎!

កៈ ចាសអ៊ុំ ហើយអ៊ុំគិតថា....

ខៈ (គាត់ក្អក)!

កៈ
ពេលដែលអ៊ុំរៀបការកាលជំនាន់មុនហើយនឹងឥលូវនឹងអ៊ុំឃើញថាវាខុសគ្នាយ៉ាងណាខ្លះទៅអ៊ុំទំនៀមទំលាប់ណាស់អ៊ុំ?

ខៈ អូយ....(សើច) ខុសគ្នាឆ្ងាយណាស់ក្មួយអើយគេឥលូវនេះណាស់ បើកាលនៅជំនាន់ខ្ញុំនោះស៊ីបាយនឹងស្លឹកឈូកសោះនឹង(សំលេងកូនក្មេង) ដល់ពេលថាការ ថាហ៎ជិតការអញ្ចឹងនឹងក្មួយអីចឹងទៅ ប្អូន បង អីអញ្ចឹងទៅនាំគ្នាទៅបេះស្លឹកឈូកមកទៅដល់ពេលស៊ីទៅក៏នាំគ្នាដាក់ស្លឹកឈូកនឹងទៅ(សើច)!

កៈ (សើច) កាលនឹងគេការប៉ុន្មានថ្ងៃដែរអ៊ុំ?

ខៈ អ៊ឺមការតែមួយថ្ងៃៗនឹងឯងក្មួយ!

កៈ ចឹងហ៎អ៊ុំ?

ខៈ អានឹងដូចថាយើងទើបតែនឹងដាច់ហើយនឹងណាស់(ទើបតែដាច់ពីជំនាន់ប៉ុលពតហើយ)!

កៈ ធ្វើគ្រាន់តែបង្គ្រប់កិច្ចទេន៍អ៊ុំស្រី?

ខៈ ចាសនឹងហើយធ្វើអោយតែបង្គ្រប់កិច្ចទៅទេ!

កៈ ចាសអ៊ុំស្រី ចឹងកម្មវិធីមានអីគេខ្លះដែរអ៊ុំ(សំលេងរំខានពីខាងក្រៅ)....

ខៈ (ដេញឆ្កែ)!

កៈ សែនចងដៃ ហើយនឹងអី...

ខៈ នឹងហើយ!

កៈ ហើយនឹងហែជំនូនអីនឹងហ៎អ៊ុំ?

ខៈ មានៗ
មានអា....អត់ទេអត់មានហែជំនូនទេមានតែអាពេលដែលយើងចាប់ផ្តើមអីចឹងទៅយើងផ្ទឹមអីចឹងទៅ(សំលេងរំខានពីខាងក្រៅ)
ហើយបានទៅកាត់សក់អឺ....ទៅបេះផ្កាដូង(សំលេងរំខានពីខាងក្រៅ)
នៅចាំបាន(សើច)ទៅបេះផ្កាដូងនៅឯវត្តលោកឯណោះ

ហើយដល់ពេលដែលត្រឡប់មកវិញអីអញ្ចឹងឯងយើងដូចថាផ្ទឹមអីចឹងទៅដូចថាបាច់ផ្កាដូងអីអញ្ចឹងទៅ(សំលេងកូនក្មេង) តែប៉ុណ្ណឹងឯងណាស់ក្មួយក៏ចប់ទៅ!

ក៖ អឹម...ចាស!

ក៖ ហើយទៅក៏សែនចងដៃចងអីនឹងទៅហើយទៅសែនចងដៃមានស្អីនោះ!

ក៖ គោរក្របីហើយនឹងអង្ករ....

ខ៖ អត់!

ក៖ អត់មានទេហ៎អ៊ុំន៎?

ខ៖ អត់មានទេ សែនចងដៃតែទទេរនឹងឯងទៅណាស់(សើច)!

ក៖ (សើច) អើយអ៊ុំកំប្លែងណាស់!

ខ៖ ដល់ពេលគេមកស៊ីការអីអញ្ចឹងឯងយកអង្ករមករៀងៗខ្លួនមក!

ក៖ ចាសអ៊ុំស្រី!

ខ៖ ចឹងឯងទៅ!

ក៖ ហើយទៅឪពុកម្ដាយរបស់អ៊ុំទាំងសងខាងនឹងពួកគាត់មកដឹងលឺចឹងទៅន៎អ៊ុំ?

ខ៖ នឹងឯងម៉ែឪទាំងសងខាងគាត់មកទទួលដឹងលឺងអញ្ចឹងទៅណាស់ក្មួយ!

ក៖ កាលនឹងអ៊ុំស្រីរៀបការនឹងដូចជាមិនទាន់នឹងអាយុ២០ឆ្នាំផងទេមើលទៅអ៊ុំ?

ខ៖ ១៩ឆ្នាំនឹងអ៊ុំរៀបការ ១៨ឆ្នាំ ១៩ឆ្នាំអីនឹងណាស់ក្មួយអ៊ុំរៀបការហើយ!

ក៖ ១៨ឆ្នាំ ១៩ឆ្នាំ?

ខ៖ ១៨ឆ្នាំ ១៩ឆ្នាំនឹងណាស់ក្មួយនៅលលេល្ងើរលិករលក់នឹង!

ក៖
ចុះអ៊ុំនៅពេលដែលឪពុកម្ដាយពួកគាត់រៀបចំអោយអ៊ុំស្រីមានគូស្រករនៅអាយុរៀងនៅស្ទើរដែរ....

ខ៖ នឹងឯងក្មួយ!

កៈ យើងអាយុនឹងពេញក្រមុំហើយប៉ុន្តែគ្រាន់តែថាយើងដូចនៅមានអាយុ....

ខៈ ទៅណានឹងនោះ!

កៈ យើងនៅរៀងក្មេងណាស់អ៊ុំ?

ខៈ យើងនៅក្មេង....

កៈ តើអ៊ុំមានដូចជាបដិសេធន៍ដូចធ្លាប់គិតអី(សំលេងរំខានពីខាងក្រៅ) ផ្សេងជាមួយនឹងឪពុកម្តាយដែរឬទេចឹងណាស់អ៊ុំឬមួយក៏ពួកគាត់អោយរៀបការអ៊ុំក៏សំរេចចិត្តរៀបការតែម្តង?

ខៈ ហើយ កាលនឹងនោះខ្ញុំនៅឆោតណាស់ក្មួយអើយបើម៉ែអោយមានប្តីចេះតែមានប្តីទៅ(សើច) មិនបានទៅដឹងថាមិនទៅហ៊ានប្រកែកនឹងគាត់អីទេណាស់ក្មួយ!

កៈ អឺម!

ខៈ បើគាត់ថាអោយអ៊ុំមានប្តីក៏មានប្តីទៅ រួចហើយគាត់នឹងម្តាយរបស់ខ្ញុំនឹងគាត់ក៏ធ្វើទៅតាមអាពតផ្គួរផ្គងដែរនឹងណាស់!

កៈ អឺម....

ខៈ រួចដល់ពេលនេះទៅក៏ម៉ែឪត្រូវរូវគ្នានឹងទៅ....

គៈ ម៉ាចេញក្រៅ(សំលេងកូនក្មេង)!

កៈ អ៎.....

ខៈ នឹងឯង!

កៈ ចាសអ៊ុំស្រី ចឹងហើយក៏អ៊ុំបានរៀបការតែម្តងទៅ?

ខៈ ចាសនឹងឯងខ្ញុំក៏បានរៀបការទៅ (សំលេងរំខានពីខាងក្រៅ)!

កៈ ចាសចុះអ៊ុំកាលនឹងអ៊ុំមានធ្លាប់ដែលបានលួចស្រលាញ់គេផ្សេងអីដែរឬទេ អត់ទេន៍អ៊ុំ?

ខ៖ អូ....(សំលេងរំខានពីខាងក្រៅ) កាលនៅនឹងជំនាន់នោះណាស់មិនហ៊ានទៅស្រលាញ់អីទេបើគេមិនផ្គូរផ្គងអោយទេស្អប់ចង់ងាប់(សើច)!

ក៖ (សើច)!

ខ៖ ចឹងឯងក្មួយ គ្រាន់តែគេចំអន់លេងអីនឹងស្អប់ណាស់ជំនាន់នោះហើយអៀនច្រើនណាស់ហើយខ្មាស់ណាស់ក្មួយអើយ!

គ៖ ម៉ាខ្ញុំចេញទៅខាងក្រៅមួយណា! (សំលេងកូនក្មេងនិយាយ)!

ក៖ អឺម...ចាសអ៊ុំស្រី!

ខ៖ (សើច)!

ក៖ (សើច)!

ខ៖ ពូកែអៀនណាស់ ពូកែខ្មាស់ណាស់ដែលចំអន់លេងអីនឹងនោះមិនចូលចិត្តទេ!

ក៖ អឺម...ចាស(សើច)!

ខ៖ (សើច)!

ក៖ ហើយបានដល់ពេលឥលូវនឹងបានមានក្រុមគ្រួសារអ៊ុំហើយនឹងអ៊ុំបានរៀបការហើយក៏រស់នៅជាមួយគ្នារហូតមកទល់សព្វថ្ងៃនឹងមក?

ខ៖ នៅជាមួយគ្នារហូតទាល់តែមកដល់ឥលូវនឹងទៅណាស់ក្មួយ!

ក៖ អឺម....

ខ៖ ចេះតែរកស៊ីតេកតក់អីអញ្ចឹងទៅក្មួយ!

ក៖ ចាសអ៊ុំស្រី ហើយទៅអ៊ុំមិនដែលផ្លាស់ប្តូរមុខរបរអីន៏អ៊ុំ? អ៊ុំគិតតែពីធ្វើស្រែធ្វើចំការអីអញ្ចឹងទៅហ៎អ៊ុំ?

ខ៖ ធ្វើស្រែៗចឹងទៅដូចថាយើង...ប្តីរបស់អ៊ុំនឹងគាត់ទៅរកត្រីរកសាច់អីអញ្ចឹងទៅណាស់ក្មួយ!

កៈ ចាសអ៊ុំ!

ខៈ ហើយបើដូចយើងនៅផ្ទះចិញ្ចឹមកូននឹងឯងចាក់នំពុម្ពធ្វើដុតនំដុតអីកូនទូលលក់ចឹងទៅ!

កៈ អូ...អ៊ុំមានចាក់នំធ្វើនំលក់អីដែរហ៎អ៊ុំ?

ខៈ នឹងឯងហើយ មានលក់ឥវ៉ាន់ទៀតណាស់(សើច)!

កៈ ឥវ៉ាន់ចាប់ហួយនៅផ្ទះ....

ខៈ
នឹងឯងលក់ឥវ៉ាន់ចាប់ហួយអីចឹងឯងដល់ពេលដែលលក់ៗទៅកូនគេវារៀនធំធាត់ចឹងអស់ទៅវាបានធ្វើការរោងចក្រនឹងគេ!

កៈ អឹម....

ខៈ ទៅដល់គេបានទៅធ្វើការរោងចក្រទៅគេថាម៉ែអើយបើម៉ែឯងពិបាកពេកចិញ្ចឹមតែជ្រូកបានហើយកុំអោយហត់ពេកហើយខ្ញុំក៏ចិញ្ចឹមតែជ្រូកនឹងទៅឈប់លក់ឥវ៉ាន់នឹងទៅ!

កៈ ចាសអ៊ុំស្រី ហើយចុះឥលូវនឹងអ៊ុំឈប់លក់ឥវ៉ាន់ហើយហ៎អ៊ុំ?

ខៈ ឈប់លក់ហើយក្មួយ ខ្ញុំឈប់លក់ហើយឥលូវនឹងណាស់!

កៈ ចាសអ៊ុំ វាចំណេញតិចពេកហ៎អ៊ុំ?

ខៈ នឹងហើយចំណេញតិចពេកក្មួយអើយកាលនឹងយើងវាមានកូននឹងច្រើនណាស់!

កៈ (សើច)
ស្រួលមិនស្រួលនឹងពួកគាត់នាំគ្នាអង្គុយញ៉ាំអស់រលីងមានឥវ៉ាន់ចាប់ហួយចឹង(សើច)!

ខៈ (សើច) នឹងឯង(សើច)!

កៈ
ចាសអ៊ុំហើយអ៊ុំក្នុងចំណោមការងារទាំងអស់នឹងអ៊ុំគិតថាអ៊ុំស្រលាញ់ការងារមួយណាខ្លាំងជាងគេដែរអ៊ុំ?

ខៈ ខ្ញុំស្រលាញ់ការងារលក់ដូរខ្លាំងណាស់ក្មួយអើយ!

កៈ អឺម...ចាសអ៊ុំ!

ខៈ ប៉ុន្តែដល់ពេលឥលូវនឹងដល់ពេលដែលខ្លួនយើងវាចាស់ទៅយើងវាចេះតែឈឺដៃឈឺជើងអីនឹងវាខ្លាំងពេកណាស់!

កៈ អឺម...ចាសអ៊ុំ!

ខៈ ហើយណាមួយយើងវាមិនស្រួវជាស្រួលក្នុងខ្លួនណាមួយយើងវាចេះតែញ័រៗអីអញ្ចឹងណ្ហើយធាក់កង់ទៅយកឥវ៉ាន់មិនរួចទេបើម៉ូតូអីនឹងក៏អ៊ុំមិនចេះជិះដែរខ្ញុំណាស់(សើច)!

កៈ អត់មានអ្នកគេទៅលក់ហ៎អ៊ុំ?

ខៈ អត់មាន....

កៈ ចុះជំនាញការធ្វើនំពុម្ពលក់អីនឹងអ៊ុំស្រីចេះធ្វើខ្លួនឯងឬក៏មានអី....

ខៈ ខ្ញុំចេះធ្វើលក់ខ្លួនឯងនឹងក្មួយ!

កៈ ចាសអ៊ុំ ហើយចឹងមិនមែនអ៊ុំចេះរៀនធ្វើពីគេទេហ៎អ៊ុំ?

ខៈ អត់ទេក្មួយ អត់មានទៅមើលអ្នកណាយើងដឹងថាយើងត្រូវធ្វើមេវាមុនទៅបានយើងទៅកិនម្សៅអីអញ្ចឹងឯងទៅ
បានយើងលាយមេលាយអីចឹងឯងហើយដល់ពេលដែលម្សៅឡើងទៅយើងលាយស្ករចូលទៅក្នុងនឹងហើយមួយសន្ទុះចឹងទៅយើងចាប់ផ្តើមចាក់នំនឹងទៅណាស់!

កៈ ចាសអ៊ុំ ហើយទៅយើងមើលលើរសជាតិអីថាដាក់ប៉ុន្មានៗអីក៏ខ្លួនឯងទាំងអស់តែម៉ងហ៎អ៊ុំ?

ខៈ នឹងឯងក្មួយ ធ្វើខ្លួនយើងទាំងអស់នឹងក្មួយអត់ទៅបានរៀននឹងអ្នកណាទេ!

កៈ ចុះ....ចាសអ៊ុំស្រី ហើយមុខរបរមួយនឹងកាលដំបូងឡើយនឹងអ៊ុំស្រីមានគំនិតនឹកឃើញយ៉ាងម៉េចដែរបានជាចង់លក់នំអញ្ចឹងណាស់អ៊ុំ?

ខៈ
ហើយអ៊ុំធ្វើនៅកាលនឹងឯងនោះក្មួយហើយយើងវាអត់ណាស់ហើយដល់ពេលនេះទៅយើង

ចេះតែច្នៃវាទៅ
ចេះតែធ្វើលក់ទៅធ្វើហើយអោយកូននឹងវាដើរលក់ទៅ(សំលេងរំខានពីខាងក្រៅ)!

ក៖ អត់មានថាធ្វើនំនឹងឡើយដោយសារតែខ្លួនឯងស្រលាញ់សិល្បះធ្វើនំអីអត់ទេន៍អ៊ុំ? គឺអ៊ុំធ្វើនំនឹងឡើងដើម្បីតែផ្គត់ផ្គងជីវភាពរបស់អ៊ុំនៅពេលនឹងម៉ងហ៍?(មានសំលេងរំខានពីខាងក្រៅ)!

ខ៖ នឹងហើយ(សំលេងរំខានពីខាងក្រៅ) ដល់ពេលដែលយើងធ្វើចឹងឯងទៅវាធ្វើអោយយើងនឹងនឹកឃើញថាយើងនឹងវាអត់ខ្លាំងណាស់ទៅធ្វើបានអីអញ្ចឹងឯងទៅអោយកូននឹងដូរជាអង្ករខ្លះ
ទៅហើយយើងបានលុយយកលុយទៅណាស់!

ក៖ ចាសអ៊ុំស្រី!

ខ៖ ចាសអញ្ចឹងណាស់ក្មួយ!

ក៖ ហើយ កាលនឹងហាត់ខ្លាំងដែរឬទេអ៊ុំធ្វើនំនឹង?

ខ៖ ហើយ ហាត់ខ្លាំងណាស់ក្មួយអើយកូនតូចផង ណាមួយអ៊ុំមានចិញ្ចឹមជ្រូកផង!

ក៖ ចាសអ៊ុំស្រី ការងារច្រើនណាស់អ៊ុំកាលនឹង!

ខ៖ នឹងឯង(សើច)!

ខ៖ (សើច) សរសើរដល់អ៊ុំស្រីមែនទែន(សើច)!

ក៖ (សើច)! ហើយនៅពេលនឹងអឺ....កាលនឹងណាស់អ៊ុំៗស្រីរកប្រាក់ចំណូលបានប៉ុន្មានដែរពីការធ្វើនំលក់របស់អ៊ុំនឹងណាស់អ៊ុំ?

ខ៖ នៅកាលនឹងក្មួយហើយវាដូចថាយើងធ្វើនំនឹងលក់ផង ហើយយើងធ្វើអោយកូនស៊ីផងអីអញ្ចឹងទៅឯងបានគ្រាន់តែម៉ាទប់ទល់ៗនឹងឯងណាស់ក្មួយបានមួយថ្ងៃស៊ីមួយថ្ងៃបានមួយថ្ងៃស៊ីមួយចឹងទៅណាស់ក្មួយ!

ក៖ ចាសអ៊ុំស្រី យើងបានជុំគ្នា!

ខ៖ បានអង្ករមកអីអញ្ចឹងឯងទៅ យកខ្លះទៅដាក់ធ្វើជាម៉្សៅកិនធ្វើនំនឹងខ្លះទៅហើយនៅសល់នឹងដាំបាយស៊ីខ្លះទៅចឹងឯងណាស់ក្មួយ!

ក៖ ចាសអ៊ុំស្រី!

គ៖ ម៉ា...(សំលេងកូនក្មេងពីខាងក្រៅ)!

ខ៖ ចឹងឯងណាស់ក្មួយកាលពីកូនៗរបស់អ៊ុំនៅតូចៗនឹងអ៊ុំវេទនាខ្លាំងណាស់ក្មួយ(សើច)!

គ៖ ម៉ាបាត់ស្បែកជើងរបស់អីមួយហើយ!

ក៖ ចាសអ៊ុំស្រីត្រូវហើយអ៊ុំព្រោះអ៊ុំត្រូវការចិញ្ចឹមពួកគាត់!

ខ៖ នឹងហើយ....

ក៖ ទំម្រាំតែនឹងពួកគាត់បានធំពេញវ័យនឹង!

គ៖ ម៉ាបាត់ស្បែកជើងរបស់អីមួយហើយ ឃើញតែមួយទេ(សំលេងរបស់កូនក្មេង)!

ក៖

អ៊ុំស្រីអស្ចារ្យដែលអ៊ុំអាចនឹងចិញ្ចឹមកូនឡើងច្រើនហើយហើយអ៊ុំខិតខំតស៊ូមករហូតទល់នឹងសព្វថ្ងៃនឹងណាស់អ៊ុំ!

ខ៖ ចាសនឹងហើយក្មួយ!

ក៖ ហើយអ៊ុំបើយើងនិយាយទៅដូចជាពាក្យលោកពោល អត់ខ្ជិលណាស់អ៊ុំ?

ខ៖ នឹងហើយក្មួយ!

ក៖ ចាសអ៊ុំស្រី!

ខ៖ អូ....បើយើងហ៊ានតែខ្ជិលនឹងដឹងតែដាច់អោយកូនស៊ីហើយ(សើច)!

ក៖ (សើច)!

ខ៖ អត់មានអីអោយកូនស៊ីឥលូវនឹងហើយ(សើច) ហោឺយ!

ក៖ (សើច) ចាសអ៊ុំស្រី!

ខ៖ ទាល់តែយើងនឹងខំប្រឹងបន្តិច ប្រឹងនឹងអត់ហ៊ានឈប់សោះហើយក្មួយ!

កៈ ចាសអ៊ុំស្រី!

ខៈ ប៉ុន្តែកាលណោះដូចថាយើងវានៅមានកំលាំង កាលនឹងណោះដល់ពេល...

គៈ អើយម៉ាបាត់ៗស្បែកជើងរបស់អីម្ខាងបាត់ហើយម៉ា(សំលេងរបស់កូនក្មេង)!

កៈ អញ្ចឹងយើងអត់ធុញទ្រាន់ទេ....

គៈ ម៉ាបាត់ស្បែកជើងរបស់អីមួយហើយ(សំលេងរបស់កូនក្មេង)!

ខៈ យើងដូចថាចេះតែធ្វើទៅណាស់ក្មួយ!

គៈ នៅសល់តែមួយទេ(សំលេងរបស់កូនក្មេង)!

ខៈ ហ៊ឹម...ឆ្កែពាំទៅណាទេហី?

កៈ មិញនៅត្រង់នេះតើមិញ!

ខៈ នោះនៅឯណោះហ៎!

កៈ ចាសអ៊ុំស្រី!

ខៈ (សើច)!

កៈ ហើយ (សើច) ចឹងអ៊ុំស្រី(សើច)!

ខៈ (សើច)!

កៈ
អឺ....ទាក់ទងជាមួយនឹងការងាររបស់អ៊ុំស្រីឃើញថាអ៊ុំស្រីបានខំប្រឹងធ្វើការងារច្រើនមែនទែន!

ខៈ ចាសក្មួយ!

កៈ ហើយខំប្រឹងបង្កើតជាមុខរបរនឹងច្រើន....

ខៈ នឹងឯងក្មួយ!

កៈ
ចាសអ៊ុំហើយចុះចំណែកក្ដីស្រម៉ៃរបស់អ៊ុំវិញកាលពីតូចនឹងអ៊ុំមានក្ដីស្រម៉ៃថាចង់ធ្វើអីគេនៅពេលដែលអ៊ុំធំឡើងដែរឬទេ? (សំលេងរំខានពីខាងក្រៅ)!

ខ៖ ហើយកាលនឹងឯងនោះខ្ញុំដូចថាវាចេះតែស្រមើរស្រម៉ៃហើយ(សើច) ឃើញគេណាស់ អេ....ស្រមើរស្រម៉ៃកាលនឹងនៅជំនាន់ប៉ុលពតនឹងមិនដឹងថាគេលក់អីដូរអីធ្វើយ៉ាងម៉េចនោះទេ បើមកដល់ពេលដែលខ្ញុំមានប្ដីមានសីអីអញ្ចឹងឯងទៅហើយយើងមានកូនមានចៅអីអញ្ចឹងឯង ស្រមើរស្រម៉ៃខ្ពស់ណាស់ក្មួយ(មានសំលេងរំខានពីខាងក្រៅ) ចង់បើកកន្លែងលក់ដូរអីបានមួយឆាបអញ្ចឹងដែរ(សើច)!

គ៖ យី....(សំលេងរបស់កូនក្មេង)!

ខ៖ កាលនឹងឯងមានជ្រូកផងអីផង ណាកូននឹងផងហើយរវល់នឹងការលក់ដូរនឹងឯងផង(សំលេងរំខានពីខាងក្រៅ) ស្លាប់ហើយកាលនឹងឯងខ្ញុំគ្មានម៉ូតូអីទេឌុបតែកង់ទេ(សំលេងរំខានពីខាងក្រៅ)!

ក៖ អឹម....ចាសអ៊ុំស្រី!

ខ៖ អាអូន...អឹម!

ក៖ ចាសអ៊ុំស្រី(សំលេងរំខានពីខាងក្រៅ) ហើយអឺ...កាលនឹងអ៊ុំធ្លាប់ស្រម៉ៃដែរន៏អ៊ុំ(សំលេងរំខានពីខាងក្រៅ) ធ្លាប់មានក្ដីស្រម៉ៃថាធំឡើងចង់បើកកន្លែងលក់ដូរឥវ៉ាន់ន៏អ៊ុំ?

ខ៖ នឹងឯងក្មួយ ដូចថាយើងឃើញរកស៊ីមានបានចឹងយើងចេះតែចង់បាននឹងគេចឹងទៅណាស់ក្មួយ!

ក៖ ចាសអ៊ុំស្រី ហើយអឺ...តើក្ដីស្រម៉ៃរបស់អ៊ុំនឹងវាអាចនឹងសម្រេចបានប៉ុន្មានភាគរយហើយអ៊ុំ?

ខ៖ អឺ....ខ្ញុំវាដូចតែថាយើងនឹងវាបានសម្រេចបានខ្លះដែរណាស់!

ក៖ ចាសអ៊ុំស្រី!

ខ៖ ដល់តែពេលដែលយើងមានក្ដីស្រមើរស្រម៉ៃអញ្ចឹងទៅយើងដូចថាបានលក់ដូរអីអញ្ចឹងដែរបានខ្លះដែរនឹងណាស់!

ក៖ ចាសអ៊ុំស្រី ហើយបន្ទាប់មកក្រៅតែពីការរកស៊ីទៅលើមុខរបររបស់អ៊ុំសព្វថ្ងៃនឹងអ៊ុំមានគំរោងបង្កើនមុខរបរបង្កើនអាជីពរបស់បន្ថែមទៀតដែរឬទេអ៊ុំ?

ខ៖ អូយ....ចេះតែមានហើយក្មួយ(សើច) បើសិនជាអាចនឹងឯងខ្ញុំចង់តែថានៅពេលដែលមានលុយមានកាក់អីនឹងឯងចង់លក់ដូរម្តងទៀតនឹងណាស់(សើច)!

ក៖ អឺម....ចាសអ៊ុំស្រី! ហើយចុះចំណែកអ៊ុំធ្វើស្រែធ្វើអីនឹងអ៊ុំយ៉ាងម៉េចដែរអត់អីទេន៍អ៊ុំ?

ខ៖ ធ្វើស្រែអីអញ្ចឹងឯងសព្វថ្ងៃនឹងបាន គ្រាន់បានតែមួយហូបៗអីនឹងណាស់ក្មួយ!

ក៖ ចាសអ៊ុំស្រី ហើយទៅស្រែនឹងដាក់ស្រូវអីគេដែរអ៊ុំ?

ខ៖ ខ្ញុំដាក់ស្រូវវស្សានឹងក្មួយ ស្រូវ....

ក៖ ចាសអ៊ុំស្រីស្រូវវស្សាអ៊ុំ ប៉ុន្តែពូជស្រូវណាស់អ៊ុំ ពូជ....

ខ៖ អើយពូជស្រូវនឹងអ៊ុំដាក់ស្រូវរាំងជ័យ ដូចជាស្រូវនាងអំ ស្រូវ....ស្អីស្រូវអីទៀតទេក្មួយច្រើនណាស់ពីរបីមុខក្មួយ!

ក៖ អូ...ច្រើនមុខណាស់អ៊ុំ!

ខ៖ ស្រូវដំណើប នាងនួកអីនឹងឯងក្មួយ!

ក៖ អូ...ពូជច្រើនណាស់ន៍អ៊ុំហើយពូជទាំងអស់នឹងអ៊ុំទិញនៅឯណាមកដែរពីផ្សារមករឬក៏គេលក់មកដល់ផ្ទះម៉ងដែរអ៊ុំ?

ខ៖ អត់ទេវាដូចថាយើងធ្លាប់ធ្វើវាពីដើមមកចឹងទៅក៏យើងមាន....

ក៖ មានពូជបន្តទៅអ៊ុំហ៎...

ខ៖ យើងមានពូជបន្តចឹងមកណាស់!

ក៖ អឺម...ចាសអ៊ុំ ហើយទៅអ៊ុំធ្វើស្រែនឹងរយះពេលប៉ុន្មានឆ្នាំហើយអ៊ុំតាំងពីដាច់មកម៉ងហ៎អ៊ុំ?

ខ៖ តាំងពីដាច់នឹងមក ខ្ញុំធ្វើចាប់តាំងពីដាច់នឹងមកគឺខ្ញុំធ្វើជាប់ធ្វើតែស្រែនឹងម៉ង(សំលេងរបស់កូនក្មេងរំខាន)!

ក៖ ចាសអ៊ុំស្រី ចឹងបទពិសោធន៍របស់អ៊ុំក្នុងការធ្វើស្រែនឹងមានច្រើនឆ្នាំមកហើយន៍អ៊ុំ?

ខ៖ ចាសក្មួយខ្ញុំធ្វើស្រែនឹងជាច្រើនឆ្នាំមកហើយ!

ក៖ ចឹងអ៊ុំស្រីធ្វើស្រែនឹងក្នុងដីប៉ុន្មានហិចតាដែរទៅអ៊ុំ?

ខ៖ មិនដឹងថាដីនឹងមានប៉ុន្មានហិចតានោះទេក្មួយ យើងដូចថាយើងបានទិញដីគេខ្លះចឹងទៅ(មានសំលេងរំខានពីខាងក្រៅ) ហើយយើងបានដូចថានៅពេលដាច់នឹងគេបានចែករបបដីអោយចឹងទៅណាស់(សំលេងរំខានពីខាងក្រៅ) នឹងឯង!

ក៖ (មានសំលេងរំខានពីខាងក្រៅ) ចាសអ៊ុំស្រី ចាស!

ខ៖ ដូចថាយើងមិនដឹងថាបានដីប៉ុន្មានណាស់ចឹងណាស់ក្មួយ!

ក៖ ចាសអ៊ុំស្រី ហើយដីនឹងមើលទៅធំដែរឬទេអ៊ុំ? ធំដូចថាអឺ...លក្ខណៈថាមើលទៅដាច់កន្ទុយភ្នែកកម៉ងណាស់អ៊ុំ? (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ អ៉ឹម! មិនដល់ទេក្មួយដូចថាកាលនឹងគេចែកក្នុងមនុស្សមួយអ្នកអីអញ្ចឹងឯង(មានសំលេងរំខានពីខាងក្រៅ) ក្នុងមួយគ្រួសារអីអញ្ចឹងទៅដូចថាបានដីនឹងប្រាំម៉ែត្រឬក៏បីម៉ែត្រអីអញ្ចឹងទៅណាស់ហើយដី(មានសំលេងរំខានពីខាងក្រៅ) ក្នុងមួយកន្លែងនឹងពូជរបស់យើងវាបានដូចថាបីតៅអីបីថាំងអីចឹងណាស់ក្មួយ!

ក៖ ចាសអ៊ុំស្រី!

ខ៖ នឹងឯងក្មួយ!

ក៖ ហើយអឺ...ចឹងដី(មានសំលេងរំខានពីខាងក្រៅ) សំរាប់ធ្វើៗស្រែនឹងអ៊ុំទទួលបានផលក្នុងមួយឆ្នាំៗនឹងប៉ុន្មានដងដែរហើយទៅបានប៉ុន្មានតោនដែរទៅអ៊ុំ?

ខ៖ យើងធ្វើស្រូវវស្សានឹងឯងធ្វើចឹងនឹងយើងទទួលបានផលតែម្ដងៗទេក្មួយ!

ក៖ ចឹងហ៎អ៊ុំ(សំលេងរំខានពីខាងក្រៅ)!

ខ៖
នឹងឯងដូចថាក្នុងមួយស្រែៗអញ្ចឹងឯងដូចថាស្រែណាដូចថាធ្លាប់ជាស្រែជង្រុកយើងណាស់(មានសំលេងរំខានពីខាងក្រៅ) អាត្រង់នឹងៗ(សំលេងឆ្កែព្រួស នឹងកូនក្មេងសើច) មួយកន្លែងនឹងខ្លះទៅបាន៦០ថាំងអីចឹងទៅ!

ក៖ អឹម...ចាសអ៊ុំ!

ខ៖ ហើយបើអាត្រង់កន្លែងណាទួលអីអញ្ចឹងទៅ(មានសំលេងរំខានពីខាងក្រៅ) បានត្រឹមតែ ១៤ទៅ១៥ថាំង ហើយខ្លះទៅបានពី ៤ ទៅ ១០ថាំងអីអញ្ចឹងទៅណាស់ក្មួយ!

ក៖ នឹងយើងបូកសរុបក្នុងមួយឆ្នាំហ៎អ៊ុំ?

ខ៖ បាន....នឹងឯងក្មួយ(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសអ៊ុំស្រី ហើយចុះមួយថាំងស្មើរនឹងប៉ុន្មានដែរអ៊ុំ?

ខ៖ មួយថាំងហ៎ក្មួយ? (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសអ៊ុំស្រី!

ខ៖ ស្មើរនឹងអង្ករអីក្មួយ(មានសំលេងរំខានពីខាងក្រៅ) បើអង្ករវាអត់ទៀងទេក្មួយសព្វថ្ងៃនឹងណាស់បើយើងកិនចឹងទៅវាៗ(មានសំលេងរំខានពីខាងក្រៅ) បាត់ខ្លះហើយចឹងណាស់ក្មួយ!

ក៖ អឹម...ចាសអ៊ុំ!

ខ៖ ហើយបើពិដើមអញ្ចឹងឯង(មានសំលេងរំខានពីខាងក្រៅ) យើងចំបាច់ដូចថាយើងកាលនឹងនៅប្រើតៅចឹងណាស់
បើអានឹងក្មួយមួយតៅបានប្រាំបីគីឡូអង្ករអីចឹងទៅណាស់(មានសំលេងរំខានពីខាងក្រៅ) ទៅដល់ពេលឥលូវនឹងឯង....

គ៖ ណូ....(សំលេងរបស់មនុស្សពីខាងក្រៅ)!

ខ៖ នៅត្រឹមប្រាំពីរគីឡូអីនឹងឯងក្មួយអត់បានដូចមុនទេ!

កៈ អូ....ស្រកវៀងច្រើនដែរន៍អ៊ុំ?

កៈ នឹងឯងហើយចុះស្រូវតលូវនឹងអ៊ុំលក់វាចេញនឹងបានប៉ុន្មានដែរក្នុងមួយគីឡូ?

ខៈ (មានសំលេងរំខានពីខាងក្រៅ) តលូវនឹងបានប្រាំរយ ឬក៏មួយពាន់ចឹងទៅណាស់ក្មួយ!

កៈ អឹម....ចាសអ៊ុំស្រី!

ខៈ អានឹងវាដូចជាថាទៅតាមប្រភេទស្រូវទន់រ៉ឹងអីអញ្ចឹងណាស់ក្មួយ(មានសំលេងរំខានពីខាងក្រៅ)!

កៈ ចាសអ៊ុំស្រី!

ខៈ នឹងឯងក្មួយ!

កៈ នឹងហើយចុះហើយនៅពេលដែលបានតំលៃប៉ុណ្ណឹងអ៊ុំគិតថាតំលៃស្រូវប៉ុណ្ណឹងសមនឹងតម្លៃដែលអ៊ុំខំធ្វើវានឹងដែរឬទេ (មានសំលេងរំខានពីខាងក្រៅ) កំលាំងពលកម្មដែលអ៊ុំខំចំណាយធ្វើវានឹងណាស់អ៊ុំ?

ខៈ (សើច) អើយក្មួយហើយវាដូចថាវាសមដែរណាស់វាសមនឹង (មានសំលេងរំខានពីខាងក្រៅ) វាសមនឹងដូចថាគេធ្វើស្រូវប្រាំងនឹងវាច្រើន គេធ្វើស្រូវប្រាំងនឹងណាស់ ស្រូវប្រាំងនឹងច្រើនណាស់ក្មួយហើយ (មានសំលេងរំខានពីខាងក្រៅ) អោយតែជិតដល់ខែចូលឆ្នាំនឹងគេចាប់ផ្ដើមដឹងស្រូវប្រាំងមកពីវាលក្រោមហើយ....

កៈ អឹម....

ខៈ ម្នាក់ៗដូចថាគ្រាន់តែទីកើបស្រូវនឹងណាស់ក្នុងមួយប៉េ (មួយការុង) នឹងឯងគេអោយប្រាំមួយកើបស្រូវនឹងឯងមួយថ្ងៃប្រាំរយនឹងឯង (មានសំលេងរំខានពីខាងក្រៅ) វាល់ល្ងាច( តាំងពីព្រឹកទល់នឹងល្ងាច) រហូតដល់ទៅយប់ទៀតនឹងឯងទៅហើយទៅម្នាក់ៗនឹងបាន ២០០០០៛ ទៅ ៣០០០០៛ អញ្ចឹងទៅណាស់ (មានសំលេងរំខានពីខាងក្រៅ)!

កៈ អូ....បានច្រើនដែរន៍អ៊ុំ!

ខៈ ស្រូវច្រើនណាស់ក្មួយ!

ក៖ ចាសអ៊ុំស្រី!

ខ៖ ស្រូវប្រាំងណាស់!

ក៖ តែចំណែកអ៊ុំធ្វើស្រូវវស្សាអញ្ចឹងនឹងវាផ្ទុយពីស្រូវប្រាំងហើយ....

ខ៖ នឹងឯងក្មួយ!

ក៖ អញ្ចឹងពេលដែលយើងលក់ចេញនឹងមានគេប្រមូលទិញទាំងអស់ឬក៏យើងយកវាទៅលក់ដោយខ្លួនឯងដែរអ៊ុំ?

ខ៖ អត់ទេក្មួយ យើងដូចថាបើ...បើយើងចង់លក់អញ្ចឹងឯង...

ក៖ ចាសអ៊ុំស្រី!

ខ៖ ដូចថាអ្នកធ្វើម៉ាស៊ីនអញ្ចឹងណាស់អ្នក (មានសំលេងរំខានពីខាងក្រៅ) អ្នកគេកិនស្រូវម៉ាស៊ីនអញ្ចឹងណាស់គេមកទិញយើងអញ្ចឹងទៅយើងលក់អោយគេនឹងក្នុងមួយគីឡូមួយពាន់ឬក៏ក្នុងមួយគីឡូប្រាំបួនរយទៅតាមប្រភេទរបស់ស្រូវយើងនឹងដូចថាស្រូវធ្ងន់ ស្រូវរ៉ឹង ស្រូវច្រៀយអញ្ចឹងទៅណាស់...ស្រូវទន់អញ្ចឹងទៅណាស់ក្មួយ!

ក៖ អូ...អញ្ចឹងគេមើលទៅលើតាមប្រភេទស្រូវទៀតន៍អ៊ុំ?

ខ៖ នឹងហើយក្មួយ គេមើលទៅតាមប្រភេទស្រូវនឹងឯង!

ក៖ ហើយពូជស្រូវផ្សេងៗ....

ខ៖ នឹងឯងក្មួយដូចថាបើជាប្រភេទស្រូវដំណើបអីនឹងយើងលក់វាបានថ្លៃអញ្ចឹងទៅក្នុងមួយគីឡូនឹងយើងអាចលក់បាន ១១០០ៗរ ទៅ ១២០០រ អីនឹងឯងណាស់ក្មួយ ហើយបើថាស្រូវខ្សាយអញ្ចឹងទៅពេលដែលយើងហូបទៅវារ៉ឹងអញ្ចឹងទៅនឹងបានក្នុងមួយគីឡូនឹងបានជូនណាទៅបាន មួយពាន់ ហើយជូនណាទៅបាន ប្រាំបួនរយអញ្ចឹងទៅណាស់ក្មួយ!

ក៖ ចាសហើយចុះស្រូវនឹងយើងដឹងថារ៉ឹងឬក៏ទន់អីនឹងយើងមើលវាតាមពូជឬមួយក៏យើងស្ទាបនឹងដៃអ៊ុំ? (សំលេងកូនក្មេងសើច)!

ខ៖ មិនមែនទេយើងដូចថាយើងគ្រាន់តែបង្ហាញគេនឹង (មានសំលេងរំខានពីខាងក្រៅ) ទៅដូចថាឈ្មួញនឹងឯងគេដឹងតែម្តង...

ក៖ គេតែម្តងហ៎អ៊ុំ?

ខ៖ នឹងឯងក្មួយ!

ក៖ អូ....ព្រោះអីគេធ្លាប់ធ្វើន៍អ៊ុំ?

ខ៖ នឹងហើយដូចថាហ៎អានេះស្រូវរាំងជ័យ ហើយអានោះស្រូវរំដួលអញ្ចឹងទៅគេស្គាល់ហើយ!

ក៖ អឺម...ចាសអ៊ុំស្រី!

ខ៖ ចាស អញ្ចឹងឯងក្មួយ!

ក៖ ចាសអ៊ុំស្រី ហើយបើតាមប្រភេទស្រូវដែលអ៊ុំធ្លាប់បានធ្វើណាស់ អ៊ុំគិតថាប្រភេទស្រូវណាដែលឆ្ងាញ់ជាងគេហើយគុណភាពហើយទទួលបានទិដ្ឋផលនឹងខ្ពស់ទៀតណាស់អ៊ុំ?

ខ៖ ស្រូវរំដួលក្មួយ (មានសំលេងរំខានពីខាងក្រៅ)!

ក៖ រំដួលហ៎អ៊ុំ?

ខ៖ នឹងឯងក្មួយហើយ....

ក៖ ស្រូវ....

ខ៖ បាយវិញក្រអូបណាស់អានឹងឯងណាស់!

ក៖ ចាសអ៊ុំស្រី!

ខ៖ បាយក្រអូបណាស់ ឡើងទន់...

ក៖ ហើយទៅអ៊ុំសព្វថ្ងៃនៅតែធ្វើវានឹងរហូតហ៎អ៊ុំស្រូវរំដួលនឹងណាស់អ៊ុំ?

ខ៖ (សើច) វាដូចថាយើងធ្វើវាបានតិចបានច្រើនអញ្ចឹងទៅណាស់ក្មួយ បើយើងដូចជាថាយើងធ្វើបានច្រើនអញ្ចឹងទៅយើងបានហូបអានឹង(ហូបអង្ករំដួល) បានយូរទៅហើយបើសិនជាយើងធ្វើវាបានតិចយើងក៏ហូបវាបានតិចចឹងដែរទៅណាស់ក្មួយ!

ក៖ ចាស....ចាសអ៊ុំស្រី ខ្ញុំឆ្ងល់មួយអញ្ចេកអ៊ុំដាំប្រភេទស្រូវច្រើនមុខដូចមិញនឹងមានច្រើនណាស់ (មានសំលេងរំខានពីខាងក្រៅ)

មានរំដួលផងអីផងម៉ាគគោកហើយហើយចឹងស្រូវទាំងអស់នឹងយើងដាំវាក្នុងមួយឆ្នាំឬក៏យើងដាំផ្សេងៗគ្នាក្នុងមួយឆ្នាំចឹងយើងដាំដចម្រុះដែរអ៊ុំ?

ខ៖ អត់ទេយើងដូចថាយើងធ្វើក្នុងរដូវអញ្ចឹងឯងនឹងយើងធ្វើទាំងអស់នឹងម៉ងរួចដូចថាមួយប្លង់នេះអញ្ចឹងឯងទៅយើងដាក់ដាំស្រូវរំដួលទៅ ហើយមួយប្លង់ខាងនោះទៅដាក់ស្រូវរាំងជ័យអញ្ចឹងឯងទៅ(មានសំលេងរំខាងពីខាងក្រៅ)!

ក៖ អូ...

ខ៖ នឹងឯង!

ក៖ ចាសអ៊ុំ ហើយចុះក្នុងមួយប្លង់នឹងមានប៉ុន្មានហិចតាដែរអ៊ុំ ប៉ុន្មានៗ....

ខ៖ វា...វាដូចថាមិនកំណត់ហិចតាទេក្មួយវាដូចថា.....

ក៖ យើងកំណត់វាបានជាផងវិញហ្អែសអ៊ុំ? ឬក៏ម៉េចយើងកំណត់ដូចថាក្នុងមួយកន្លែងនឹងយើងកំណត់ថាអោយវាបានប៉ុន្មានគីឡូអញ្ចឹងស្រូវណាស់អ៊ុំ (មានសំលេងរំខានពីខាងក្រៅ) ចឹងវិញហ៎អ៊ុំ?

ខ៖ មិនមែនទេក្មួយ យើងមិនអាចដឹងថាមួយកន្លែងនឹងបានប៉ុន្មានគីឡូទេតែដូចយើងធ្លាប់តែវាល់ស្រូវនឹងថាំងអីចឹងណាស់ (សំលេងកូនក្មេងក្អក) វាល់តៅអញ្ចឹងឯងទៅដូចថាមួយកន្លែងអញ្ចឹងទៅយើងបានបួនទៅប្រាំថាំង បួន ដប់ថាំងទៅស្រូវស្រែដែលយើងល្អនឹងឯងស្រូវជង្រុកអញ្ចឹងឯងដូចថាមានបឹងទំពាំងអីចឹងទៅយើងវាត្រូវបានច្រើនចឹងទៅណាស់!

ក៖ អឺម....ចាសអ៊ុំ! ហើយមុខរបរទាំងអស់នឹងអ៊ុំដូចថាការធ្វើស្រែធ្វើអីនឹងវាបានផ្តល់ការលំបាកនឹងទៅដល់អ៊ុំខ្លាំងដែរឬទេអ៊ុំ?

ខ៖ លំបាកដែរប៉ុន្តែធ្វើម៉េចបើយើងរស់ដោយសារតែការធ្វើស្រែនឹងឯងយើងមានតែត្រូវតស៊ូធ្វើស្រែនឹងទៅណាស់ក្មួយ ខំប្រឹងដូចថា(មានសំលេងរំខានពីខាងក្រៅ) យើងធ្វើរួចហើយអញ្ចឹងឯងទឹកលិចទឹកអីញ្ចឹងណាស់ដល់ពេលទឹកលិចហើយអញ្ចឹងទៅវាលំ

ពែងហើយអញ្ចឹងយើងទៅឆ្លកវាទៅ(យកសំនាបទៅបំពេញកន្លែងខូច) ទៅឆ្លកនឹងទៅហើយដកស្មៅដកអីចឹងទៅខ្ជិលណាស់ហាចឹងឯងណាស់ក្មួយ!

ក៖ យើងត្រូវមើលថែដីនឹងអោយបានល្អន៍អ៊ុំ?

ខ៖ នឹងឯងក្មួយ! ចាសអ៊ុំស្រី ហើយទៅអី....ជំនាញធ្វើស្រែនឹងបានពីជីដូនជីតានឹងបន្តគ្នារហូតហ៎អ៊ុំ?

ខ៖ នឹងហើយក្មួយបានមកបន្តគ្នាពីដូនពីតាពីម៉ែពីឪយើងនឹងមកធ្វើស្រែក៏ធ្វើស្រែនឹងមកជាប់រហូតនឹងមកណាស់!

ក៖ អ៊ឹម! ចាសហើយទៅដីដែលអ៊ុំធ្វើនឹងក៏នៅសល់ពីជីដូនជីតាមកដែរហ៎អ៊ុំ?

ខ៖ មិនមែនទេក្មួយ (មានសំលេងរំខានពីខាងក្រៅ) ដីនឹងឯងដូចថាយើង....

ក៖ រដ្ឋចែកអោយយើងធ្វើ....

ខ៖ រដ្ឋចែកអោយទេដូចថាយើងបានប្តីប្រពន្ធអញ្ចឹងហើយយើងបានបែកពីពួកគាត់ហើយហើយនៅកាលនឹងឯងម៉ែឪរបស់យើងក៏ពួកគាត់គ្មានទៅសល់កេរ្តិ៍ពីដូនតាមកដែរណាស់ក្មួយ!

ក៖ ចាសអ៊ុំដូចថាយើងដាច់ពីត្រឹមជំនាន់ប៉ុលពតនឹងមកម៉ង?

ខ៖ នឹងហើយបើដាច់ពីជំនាន់ប៉ុលពតនឹងមកវាលៃចែកគ្នា(មានសំលេងរំខានពីខាងក្រៅ)!

ក៖ អស់ហើយ!

ខ៖ អស់ហើយ(មានសំលេងរំខានពីខាងក្រៅ) គ្មានអោយនៅសល់អីទេ!

ក៖ អ៊ឹម....ចាសស្តាយណាស់អ៊ុំគ្មានបាននៅសល់កេរ្តិ៍ពីជំនាន់មុននឹងទេ(សើច) ន៍អ៊ុំ?

ខ៖ គ្មានកេរ្តិ៍ពីជំនាន់មុនទេ (មានសំលេងរំខានពីខាងក្រៅ) មានតែដាច់ហើយនឹងឯងទៅបានកេរ្តិ៍ដាច់ហើយនឹងទេ(មានសំលេងរំខានពីខាងក្រៅ)
អី...វៃវាអោយឆ្ងាយទៅអាអូន(និយាយខាងក្រៅការសំភាសន៍)!

ក៖ (សើច) អេ...ប្រយ័ត្នវាខាំណាស់!

ខ៖ កុំចាប់វាអាអូន បានហើយកុំធ្វើវា(សំលេងឆ្កែស្រែ) អីយ៉ូយ....(សំលេងកូនក្មេង) អាអ្នកនឹងឯង(សើច) ក៏រពឹសចំណាប់ណាស់ដែរនឹងណាស់ (សំលេងកូនក្មេងសើច)!

ក៖ ត្រូវជាចៅរបស់អ៊ុំហ៎អ៊ុំ?

ខ៖ ចៅ.....

ក៖ ចាសអ៊ុំស្រី ហើយទៅអ៊ុំខ្ញុំសូមធ្វើការសំភាសន៍បន្តទៅទៀតទាក់ទងជាមួយនឹងមុខរបរអ៊ុំទាំងអស់នឹងដូចថាមានទាំងការ(សំលេងកូនក្មេង) ធ្វើស្រែចំការផង ចិញ្ចឹមសត្វ ហើយលក់នំពុម្ពផង ហើយមានលក់ឥវ៉ាន់ចាប់ហួយទៀត (មានសំលេងរំខានពីខាងក្រៅ)....

ខ៖ (សើច)!

ក៖ ឥលូវនឹងគឺរួមកគឺអ៊ុំស្រីធ្វើតែស្រែមួយមុខនឹងទេ?

ខ៖ ចាសក្មួយ!

ក៖ លែងធ្វើអស់ហើយ....

ខ៖ លែងអស់ហើយដូចថាយើងចិញ្ចឹមជ្រូកអីដូចថាយើងធ្លាប់ចិញ្ចឹមអញ្ចឹងទៅណាស់យើងទំលាក់ជ្រូកទំលាក់ដូចថា (សំលេងឆ្កែ) ឥវ៉ាន់ដែលយើងធ្លាប់លក់ដូរអីអញ្ចឹងឯងនឹងយើងទំលាក់ចោលហើយទំលាក់សិនទៅយើងអត់មានធ្វើរកអីទេមានតែចិញ្ចឹម អ៎...រក...ធ្វើស្រែនឹងណាស់ក្មួយ (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសអ៊ុំស្រី!

គ៖ ឆ្កែៗ....(សំលេងកូនក្មេង)!

ខ៖ មានតែធ្វើស្រែនឹងណាស់ ធ្វើស្រែនឹងចឹងទៅយើងចិញ្ចឹមមាន់ទាតិចតួចអញ្ចឹងទៅ(មានសំលេងកូនក្មេង) គោអញ្ចឹងទៅ!

ក៖ ចាសទុកគ្រាន់បានជួយសំរួលទៅដល់ជីវភាពដែរន៍អ៊ុំ?

ខ៖ ចាសនឹងឯង!

កៈ ចាសអ៊ុំស្រី! ហើយអឺ...អញ្ចឹងអ៊ុំទាក់ទងជាមួយនឹងការងារដែលអ៊ុំបានធ្វើហើយការរកកំរៃបានអីនឹងវាអាចជួយទៅដល់ក្រុមគ្រួសាររបស់អ៊ុំហើយនឹងអ៊ុំតាំងពីមុននឹងរហូតមកដល់ឥលូវនឹងបានខ្លះៗដែរហើយ (មានសំលេងរំខានពីខាងក្រៅ) នឹងអឺ....ក្រុមគ្រួសារកូនចៅអីនឹងអ៊ុំគិតថាអ៊ុំមានគោលបំណងចង់អោយពួកគាត់ធ្វើអីផ្សេងដែរឬទេទៅថ្ងៃអនាគតណាស់អ៊ុំ ដូចថាអ៊ុំមានគំរោងសំរាប់ពួកគាត់តែម្តងណាស់អ៊ុំ?

ខៈ អឺ....

កៈ អ៊ុំមានដែលធ្លាប់គិតដែរឬទេ?

ខៈ ធ្លាប់ក្មួយអើយ ចង់ណាស់ប៉ុន្តែដូចជាថាយើងមានដើមចុងអីនឹងឯងអោយកូនអីអញ្ចឹងណាស់ដូចថាអនាគតហ៎អញ្ចឹងហីក្មួយ?
រឿងដូចថារឿងអនាគតអីអញ្ចឹងឯងចង់អោយតែកូនមានបានអញ្ចឹងម៉េចក៏មិនចង់ក្មួយ!

កៈ អ៊ឺម....ពួកគាត់ចង់ធ្វើអីក៏ធ្វើទៅអោយតែបានន៍អ៊ុំ?

ខៈ នឹងឯងក្មួយចង់រកអីចង់ធ្វើអី....

កៈ តាមបំណងរបស់គាត់ទៅ!

ខៈ ទៅតាមចំណេះវិជ្ជារបស់កូនទៅណាស់ក្មួយ!

កៈ ចាសអ៊ុំស្រី! អត់មានដូច អ៊ឹម! កូននេះរៀនចប់ទៅធ្វើពេទ្យទៅហើយនោះរៀនចប់ត្រូវទៅរកស៊ីរកអីទៅណាស់...

ខៈ (សើច)!

កៈ អត់ដែលគិតអញ្ចឹងទេន៍អ៊ុំ?

ខៈ មិនដែលទេក្មួយ!

កៈ ចាសអ៊ុំស្រី!

ខៈ កូនដូចថាបុណ្យសំណាងរបស់គេមានអញ្ចឹងទៅគេមានដូចតែថា(សំលេងឆ្កែព្រូស) ធ្វើរកកើតបានជាមុខរបរអីផ្សេងៗទៅអញ្ចឹងទៅនឹងក៏ទៅតាមកូនអញ្ចឹងទៅណាស់ក្មួយ!

កៈ អឹម....ចាសអ៊ុំស្រី!

គៈ ម៉ាពស់ ឆ្កែព្រួសមិញនឹងពស់ហាស់ម៉ា (សំលេងកូនក្មេង)!

កៈ (សើច) នឹងហើយអ៊ុំតាម...

គៈ ខ្ញុំមិនដែលឃើញពស់ទេ! (សំលេងរបស់កូនក្មេង)!

កៈ រយៈបទពិសោធន៏របស់អ៊ុំនឹងច្រើនមែនទែនតាំងពីមុនរហូតដល់ឥលូវ...តាំងពីក្មេងរហូតមកដល់ឥលូវនឹងគឺច្រើនណាស់!

ខៈ ចាសក្មួយ!

កៈ ចឹងអ៊ុំខ្ញុំចង់សួរពីជីវិតរបស់អ៊ុំតាំងពីក្មេងៗនឹងមក (សំលេងកូក) ជីវិតរបស់ក្មេងកាលពីសម័យមុននឹងយ៉ាងម៉េចដែរទៅអ៊ុំ? អ៊ុំមានការចងចាំអីគេខ្លះដែរ?

ខៈ ខ្ញុំកាលដែលខ្ញុំនៅក្មេងៗនឹងឯងខ្ញុំនៅតូចៗនឹងឯងខ្ញុំអត់មានឪពុកទេណាស់ដូចខ្ញុំបានថាអញ្ចឹងឯងម្តាយរបស់ខ្ញុំនឹងឯងគាត់ធ្វើលតធ្វើអីអោយលក់នោះណាស់!

កៈ អឹម...ចាសអ៊ុំស្រី!

ខៈ នឹងឯងក្មួយ ហើយក្មួយហើយ(គាត់ដង្ហើមធំ)!

កៈ ចាសកាលនឹងអ៊ុំស្រីចូលចិត្តលេងល្បែងអីគេខ្លះដែរអ៊ុំកាលពីអ៊ុំនៅក្មេងៗណាស់អ៊ុំ?

ខៈ មិនដឹងលេងល្បែងអីទេខ្ញុំមិនចេះលេងទេល្បែងដូចថាលេងបៀរលេងអាប៉ោងអីនឹងម៉េចនឹងខ្ញុំមិនដែលលេងទេមិនចេះលេងទេម៉ាអាយ៉ូយជីវិតទៅហើយ(មួយជីវិតរបស់អ៊ុំស្រីគាត់មិនចេះលេងល្បែងស៊ីសងទេ)!

កៈ ចាសអ៊ុំស្រី (មានសំលេងរំខានពីខាងក្រៅ) ហើយចុះអឺ....ទាក់ទងជាមួយនឹងបទចំរៀងកាលពីសម័យពីដើមអ៊ុំចូលចិត្តស្តាប់ដែរឬទេ? (មានសំលេងរំខានពីខាងក្រៅ)!

កៈ (សើច) បទចំរៀង....ខ្ញុំសព្វថ្ងៃនឹងបើនិយាយការមើលទូរទស្សន៍អីនឹងឯងចេះតែមើលៗទៅដូចថាឃើ

ងមើលពតិមានអីចឹងណាស់ហើយ (មានសំលេងរំខានពីខាងក្រៅ) បើដូចសាច់រឿងគេអីនឹងយើងមើលៗខ្លះៗទៅយើងចេះតែមើលៗចោលទេ ខ្ញុំដូចថាមិនសូវជាចូលចិត្តខាងល្បែងអីអញ្ចឹងៗណាស់(មានសំលេងរំខានពីខាងក្រៅ) វាមិនបានជាយកចិត្តទុកដាក់អីទេក្មួយ (សំលេងរបស់កូនក្មេងសើច)!

ក៖ អ៊ឹម....ចាសអ៊ុំស្រី! តែបទចំរៀងកាលពីសម័យពីដើមនឹងអ៊ុំស្រីធ្លាប់ស្តាប់ន៍អ៊ុំ? ឬក៏អ៊ុំអត់ដែលបានស្តាប់ទេអ៊ុំ?

ខ៖ បានស្តាប់ដែរណាស់គេច្រៀងអា អី...ពពិចចៀបអីនឹង អាម៉េចត្រង់ណាត្រង់ណើអីនឹងដឹងដែរណាស់!

ក៖ ចាសអ៊ុំស្រី!

ខ៖ អានឹងកាលពីជំនានពីមុនណាស់ក្មួយ (សើច)!

ក៖ ចាសអ៊ុំស្រី!

ខ៖ នឹងឯងផ្ការំចេកផ្ការំចង់អីណាណើនោះណាស់ក្មួយ!

ក៖ (សំលេងរំខានពីខាងក្រៅ) ចាសអ៊ុំស្រី!

ខ៖ កាលនឹងនោះ!

ក៖ កាលនឹងអ៊ុំ....

ខ៖ មិនដូចជាសម័យយើងឥលូវនឹងណា(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសអ៊ុំស្រី!

ខ៖ គេស្រទន់ណាស់បទចំរៀងពីដើមណាស់ ដល់ពេលយើង (មានសំលេងរំខានពីខាងក្រៅ) ឥលូវនេះឯង (សើច) គេដូចតែថា....(សំលេងរបស់កូនក្មេងសើច) អ៊ឹម...ឆ្អែទៅវិញ!

ក៖ អ៊ឹម....

ខ៖ (សើច) បទញាក់បទញ័រគគ្រើកទឹកគគ្រើកដី!

ក៖ (សើច)!

ខ៖ (សើច)!

ក៖ ចាសអ៊ុំស្រី! ហើយកាលសម័យនឹងនឹងសម័យនេះបើសិនជាធៀបវិញសម័យនឹងហើយនិងសម័យមុននឹង (មានសំលេងរំខានពីខាងក្រៅ) អ៊ុំចូលចិត្តសម័យមុនច្រើនជាងហើយត្រូវហ្អែសអ៊ុំ? បទចំរៀងណាស់អ៊ុំ? (សំលេងឆ្កែព្រួស)!

ខ៖ មែននឹងឯងខ្ញុំចូលចិត្តបទចំរៀងកាលពីសម័យមុននឹងច្រើនជាងសម័យគេឥលូវនេះគេដូចថា គេដូចតែថាវាដូចជាបទញាក់ញ័រអីនឹងវាច្រើនពេកទៅដល់តែពេលស្តាប់ៗទៅដូចជា....

ក៖ ស្តាប់អត់ចូលត្រចៀក!

ខ៖ (សើច)!

ក៖ (សើច) អត់ត្រូវចិត្តន៏អ៊ុំ?

ខ៖ វាដូចជាក្តិងក្តងពេកនឹងទៅ វាទៅជាថ្លង់ទៅវិញណាស់មិន....

ក៖ ខុសគ្នា(សើច)!

ខ៖ វាមិនចូលចិត្ត(សើច)!

ក៖ ខុសជំនាន់(សើច)!

ខ៖ នឹងឯង!

ក៖ ហើយសម័យកាលមុន....

ខ៖ ឥលូវនឹងឯង ក្មេងឥលូវនឹងឯងគេថាយើងចាស់បុរាណៗមិនសូវចូលចិត្តណាស់!

ក៖ ចាសអ៊ុំស្រី (សើច)!

ខ៖ (សើច)!

ក៖ អ៊ឹម....ចាសអ៊ុំស្រី! និយាយទៅការពេញនិយមនឹងគឺវាទៅតាមសម័យកាលមានជាជំណាក់កាលនីមួយៗណាស់អ៊ុំ ហើយកាលសម័យអ៊ុំស្រីអីនឹងចឹងបទចំរៀងអ្នកចំរៀងរូបណាដែលជាអ្នកចំរៀងដែលអ៊ុំស្រីចូលចិត្តជាងគេណាស់អ៊ុំ?

ខ៖ ហើយ! ខ្ញុំគ្មានស្គាល់អ្នកចំរៀងណាទេក្មួយ!

ក៖ អត់ស្គាល់ទេហ៎អ៊ុំ?

ខ៖ អត់ស្គាល់ទេធ្លាប់លឺសូរគេច្រៀងមកដូចជាគេច្រៀងបទអីដូចជាបទពពិចចៀបអីចឹងទៅផ្ការំចេកអីឯណាឯណីចឹងនឹងឯងទៅហើយទៅខ្ញុំដឹងតែប៉ុណ្ណឹងឯងទៅអោយដូចថាគេចំរៀងពីដើមច្រៀងអីវាមិនចាំគេនឹងប៉ុន្តែវាមិនដឹងថាអ្នកចំរៀងរូបណាច្រៀងជាចំរៀងរបស់អ្នកនេះអ្នកនោះនឹងគឺអត់ស្គាល់ទេដូចថាយើងវាមិនចាំនឹងគេណាស់ក្មួយ!

ក៖ ចាសអ៊ុំស្រី!

ខ៖ អត់ចាំទេក្មួយ!

ក៖ អឺ....ហើយទៅអ៊ុំស្រីទាក់ទងជាមួយនឹងបទពិសោធន៍ដែលល្អៗដែលមាននៅក្នុងជីវិតរបស់អ៊ុំស្រីមានដែរឬទេ? (មានសំលេងរំខានពីខាងក្រៅ)! តាំងពីមុនរហូតមកដល់ឥលូវនឹងដែលធ្វើអោយអ៊ុំសប្បាយចិត្តណាស់អ៊ុំដែលធ្វើអោយអ៊ុំនឹកឃើញហើយធ្វើអ៊ុំ (មានសំលេងរំខានពីខាងក្រៅ) សប្បាយចិត្តនឹងមានដែរឬទេ?

ខ៖ ខ្ញុំកាលពីកូននៅតូចៗនឹងខ្ញុំពិបាកចិត្តណាស់ក្មួយហើយ(មានសំលេងរំខានពីខាងក្រៅ) ហើយដល់ពេលមកសព្វថ្ងៃនឹងកូនមានប្តីមានប្រពន្ធខ្លះអញ្ចឹង ឯងទៅកូនដូចថារៀនសូត្រអីចេះដឹងខ្លះអញ្ចឹង ឯងទៅវាសប្បាយចិត្តដែរណាស់ដូចថាដឹងថាកូននឹងឯងមានប្តីមានប្រពន្ធខ្លះហើយៗរៀនសូត្រនឹងក៏ចេះខ្លះដែរវាគ្រាន់ដូចថារំដោះខ្លះដែរចឹងណាស់ដូចថាពិបាកកាលដែលពីកាលកូនៗនឹងវាតូចៗណាស់ក្មួយ កាលពីកូននៅតូចវាមិនសូវសប្បាយចិត្តទេ!

ក៖ អឺម....ចាសអ៊ុំស្រី! ចុះចំណែករឿងដែលពិបាកវិញរឿងដែលធ្វើអោយអ៊ុំពិបាកចិត្តណាស់អ៊ុំមានរឿងអីខ្លះដែរអ៊ុំ?

ខ៖ មានរឿងតែកូននឹងឯងក្មួយ នឹកឃើញថាកាលពីកូនៗនឹងតូចៗចឹងឯងព្រួយចិត្តដែលយើងវាក្រណាស់ ដែលយើងវាអត់នឹងកាលនឹងខ្លាចថាកូនឈឺមានជំងឺ ខ្លាចថារកអីអោយកូនហូបមិនបានចឹងទៅណាស់ក្មួយអញ្ចឹងទៅ!

ក៖ ចាសអ៊ុំស្រី!

ខ៖ ដល់ពេលដែលយើងដូចថារកបានមកមួយជំនាន់នេះទៀតយើងធ្វើស្រែធ្វើស្រូវអីអញ្ចឹងទៅបានកើតចឹងទៅហើយកូនក៏វាធំធាត់អស់គេមានប្ដីមានប្រពន្ធនឹងអស់អញ្ចឹងទៅហើយគេរៀនចេះខ្លះអញ្ចឹងទៅវាដូចថាវាធូរយើងគិតណាស់ក្មួយ យើងមិនសូវគិតវាដូចថាវាដឹងខ្លះហើយ!

ក៖ ចាសអ៊ុំស្រី ហើយនៅពេលដែលកូនៗរបស់អ៊ុំរៀងបានធូរធារអីទៅឪពុកម្ដាយក៏សប្បាយចិត្តទៅតាមនឹងដែរ!

ខ៖ ចាសចឹងឯងក្មួយ(សើច)!

ក៖ ចាសអ៊ុំស្រី! ហើយទៅអ៊ុំស្រីចូលចិត្តមុខម្ហូបអីគេដែរអ៊ុំ?

ខ៖ ខ្ញុំចូលចិត្តបើសំរាប់មុខម្ហូបវិញខ្ញុំចូលចិត្តសម្លគគួរ ហើយនឹងសម្លម្ជូរគ្រឿង(សើច)!

ក៖ (សើច)!

ខ៖ ឆា ចឹងទៅណាស់ក្មួយ!

ក៖ ចាសអ៊ុំស្រី!

ខ៖ ខ្ញុំចូលចិត្តណាស់ ហើយបើអ្នកផ្ទះរបស់ខ្ញុំវិញបើថាសម្លម្ជូរគ្រឿងដូចថាសម្លប្រចាំត្រកូលចឹងសម្លគគួរអីណាស់ក្មួយ!

ក៖ ចាសអ៊ុំស្រី!

ខ៖ (សើច)!

ក៖ (សើច) ចាសអ៊ុំស្រី!

ខ៖ នឹងចូលចិត្តណាស់!

ក៖ ចាសអ៊ុំស្រី! ហើយទៅអ៊ុំនឹងទាក់ទងជាមួយនឹងមុខម្ហូបអីនឹងហើយចុះបង្អែមវិញអ៊ុំចូលចិត្តបង្អែមអីដែរអ៊ុំ?

ខ៖ បើបង្អែមអីវិញនឹងចូលចិត្តដែរចូលចិត្តលតចូលចិត្តដូចនំបាញ់ចំនៀកអីចឹងណាស់ក្មួយ (សើច)!

ក៖ (សើច) ចាសអ៊ុំស្រីនៅមានតទៀត!

ខ៖ ចូលចិត្តអញ្ចឹងឯង ចាស!

ក៖ ចាសអ៊ុំស្រី ហើយចុះចំណែកផ្លែឈើផ្លែអីនឹងអ៊ុំចូលចិត្តដែរឬទេអ៊ុំ?

ខ៖ ផ្លែឈើអីវិញនឹងឯងខ្ញុំចូលចិត្តផ្លែខ្នុរក្មួយ!

ក៖ ចាសអ៊ុំស្រី!

ខ៖ ខ្ញុំណាស់ និយាយថាផ្លែខ្នុរនឹងចូលចិត្តណាស់....

ក៖ ចូលចិត្តជាងផ្លែសេរីហ៍អ៊ុំ (សើច)!

ខ៖ ហើយផ្លែខ្នុរតល្ងវនេះអត់ដូចមុនទេ ថ្ងៃមុននឹងទិញស៊ីរាគអាចមិមួយយផ្ទះ!

ក៖ (សើច) អ៊ុំទិញប៉ះចំខ្នុរគេដាក់ថ្នាំហើយអ៊ុំ!

ខ៖ (សើច) ដឹងជាប៉ះចំស្អីក្មួយ បើចេះតែទិញខ្នុរនឹងមួយមកនឹងឯងហើយខ្ទងនឹងគេខ្ទងមួយដុំចឹងណាស់ចោលទៅ ហើយឯងនោះក្រែងលរ វាទង្គិចទង្គើរគ្នាអីទេដឹងហើយគេដាក់ថ្នាំមិនដាក់ថ្នាំអីយើងវាមិនដឹងដែរដល់ពេលហូបទៅវារាគអាចមិ(សើច) យើងម៉េចដឹង មានតែរកថ្នាំលេបនឹងទៅ (សើច)!

ក៖ (សើច) ចាសអ៊ុំស្រី!

ខ៖ មិនដឹងថាគេដាក់ថ្នាំឬក៏មិនដាក់ថ្នាំ!

ក៖ ចាសអ៊ុំស្រី! ចឹងអរគុណអ៊ុំច្រើន!

ខ៖ ចាសក្មួយ!

ក៖ អឺ....ទាក់ទងនឹងអ្វីដែលជាសំណូមពរឬក៏អ្វីដែលជាការផ្ដែផ្ដាំរបស់អ៊ុំទៅកាន់ក្មេងជំនាន់ក្រោយ

នឹងជាពិសេសអឺ...ទៅដល់កូនរបស់អ៊ុំស្រីផ្ទាល់ដែលពួកគាត់បានស្តាប់នឹងតើអ៊ុំមានពាក្យពេចជ៍អ្វីដើម្បីនិយាយទៅកាន់ពួកគាត់ដែរឬទេអ៊ុំស្រី?

ខ៖ (សើច) មានពាក្យអីទេក្មួយហើយអោយតែកូនខំប្រឹងរៀងយកតំរិះយកបញ្ញាទៅណាស់មានតែតំរិះមានតែបញ្ញារបស់កូននឹងហើយដល់ពេលកូនរបស់យើងដូចថាពីដើមនឹងវាអត់រៀនអត់ចេះដឹងអីទេហើយដល់ឥលូវវារៀនចេះដឹងហើយអោយកូននឹងខំប្រឹងរៀនយកតំរិះទៅកុំអោយដូចយើងពេលមានកូនមានប្តីអញ្ចឹងឯងទៅវាក្រពិបាកអីចឹងណាស់ (ក្អកក្រហែម)!

ក៖ អឺម....ចាសអ៊ុំស្រី! ចឹងអ៊ុំមានពាក្យអីដើម្បីនឹងបន្ថែមទៀតដែរឬទេអ៊ុំ?

ខ៖ (សើច) ប៉ុណ្ណឹងហើយក្មួយ (សើច)!

ក៖ ចាសៗអ៊ុំស្រី!

ខ៖ (សើច) បានហើយ!

ក៖ ចាសចឹងអរគុណដល់អ៊ុំច្រើនដែលថ្ងៃនេះអ៊ុំបានចំណាយពេលអោយខ្ញុំសំភាសន៍អ៊ុំនៅនឹងថ្ងៃនេះហើយខ្ញុំសូមអនុញ្ញាតយកសំលេងរបស់អ៊ុំយកទៅដាក់នៅក្នុងវេបសាយរបស់សាលានៅខាងសហរដ្ឋអាមេរិចណាស់អ៊ុំ?

ខ៖ ចាសក្មួយ!

ក៖ ដើម្បីនឹងទុកជាឯកសារនឹងទុកអោយកូនចៅជំនាន់ក្រោយទៀតគេបានស្តាប់សំលេងរបស់អ៊ុំ (មានសំលេងរំខានពីខាងក្រៅ) ចាសចឹងអរគុណដល់អ៊ុំច្រើនបើសិនជាអ៊ុំមានចម្ងល់អីអ៊ុំអាចចូលទៅស្តាប់នៅក្នុងវេបសាយនឹងទៅអ៊ុំអាចនឹងស្តាប់សំលេងរបស់អ៊ុំបានណាស់អ៊ុំ ហើយចាំខ្ញុំប្រាប់ឈ្មោះវេបសាយដល់អ៊ុំម្តងទៀតណាស់អ៊ុំ!

ខ៖ (សើច) ចាស!

ក៖ ចឹងអរគុណអ៊ុំច្រើនណាស់អ៊ុំ ចាសហើយសូមជូនពរដល់ព្រមទាំងក្រុមគ្រួសារទាំងអស់គ្នាទាំងចៅ ចៅទួតអី....

ខ៖ ចាស!

ក៖ ដែលជាជំនាន់ក្រោយៗដែលគាត់មក....

ខ៖ ខ្ញុំមិនទាន់មានចៅទួតទេ(សើច)!

ក៖ ចាសពេលដែលគាត់ជំនាន់ក្រោយៗទៀតណាស់អ៊ុំ...

ខ៖ នឹងឯង!

ក៖ ដូចថាឥលូវនឹងអ៊ុំមិនទាន់មានតែទៅដល់ជំនាន់ក្រោយៗទៀតអ៊ុំមានណាស់អ៊ុំ.....

ខ៖ ចាសក្មួយ!

ក៖ ចឹងសូមជូនពរគាត់ទាំងអស់គ្នាម៉ង(សើច) ថាអឺ...អោយពួកគាត់សុខសប្បាយមានសុភមង្គលនៅក្នុងក្រុមគ្រួសារនឹងរកស៊ីមានបានទាំងអស់គ្នាណាស់អ៊ុំ!

ខ៖ ចាសក្មួយ!

ក៖ ចាសអរគុណអ៊ុំ!